សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ក្របខណ្ឌគតិយុត្តនៃការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

| ស្រាវជ្រាវដោយ | ណែនាំដោយ |
|---|---|
| និស្សិតឈ្មោះ **លោក ម៉ិល គីមហេង** | សាស្ត្រាចារ្យបណ្ឌិត **ហាច់ ផល្លី** |
| **កញ្ញា ហេង រីចេន** | |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០២០ |
| ជំនាន់ទី ២៩ (អាហារូបករណ៍) | សរសេរសារណា ២០២៤ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ិល គីមហេង** និង **ហេង វីចេន** ជានិស្សិតឆ្នាំទី ៤ នៃថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ ជំនាន់ទី២៩ (អាហារូបករណ៍) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤។

ស្នាដៃសារណាមួយនេះ បានចេញជាលទ្ធផលឡើង ពិតណាស់ដោយសារតែមានការរួមចំណែកយ៉ាង ធំធេងពីសំណាក់ ថ្នាក់ដឹកនាំសាលា លោកសាស្ត្រាចារ្យបណ្ឌិត និងលោក លោកស្រី ដែលបានផ្តល់នូវមតិ យោបល់ដ៏មានអត្ថន័យ ឯកសារនានា និងគំនិតល្អៗ ក្នុងការជួយណែនាំដល់យើងខ្ញុំ ទើបលេចចេញជារូបរាង ប្រកបដោយលទ្ធផលល្អមួយនេះ។

## សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកអ្នកមានគុណទាំងពីរ** ដែលបានខិតខំប្រឹងប្រែង តស៊ូចិញ្ចឹមកូនៗ រហូតដល់មានថ្ងៃនេះ។ ការតស៊ូរបស់លោកអ្នកមានគុណទាំងពីរ ពុំអាចកាត់ថ្លៃបានឡើយ ដោយមានទម្ងន់ធ្ងន់ជាងប្រឹថពី។ លោកអ្នកមានគុណទាំងពីរ បានទូន្មានប្រៀនប្រដៅ កូនៗឱ្យដើរប្រកបដោយគន្លងធម៌ ចេះស្រឡាញ់យោគយល់ អធ្យាស្រ័យ និងខិតខំប្រឹងប្រែងមិនខ្លាចភាពនឿយហត់ ដើម្បីឱ្យកូនៗទទួលបាននូវចំណេះដឹងមួយខ្ពង់ខ្ពស់ ជាប្រយោជន៍សម្រាប់អនាគតដ៏ត្រចះត្រចង់ និងភ្លឺស្វាង។ លោកអ្នកមានគុណទាំងពីរ បានផ្តល់នូវក្តីស្រឡាញ់ និងណែនាំកូនៗបានយ៉ាងល្អ ទើបកូនបានក្លាយទៅជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អសម្រាប់សង្គមជាតិទាំងមូល។ កូនៗសូមថ្លែងអំណរគុណនូវទឹកចិត្តដ៏មានតម្លៃរបស់ លោកអ្នកមានគុណទាំងពីរជាក្រៃលែង។

## យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ

ថ្នាក់ដឹកនាំ គណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំបង្រៀន និងផ្តល់នូវគំនិតអប់រំល្អៗដល់និស្សិតគ្រប់រូប។ សូមថ្លែង អំណរគុណទឹកចិត្តនៃការលះបង់ និងខិតខំក្នុងការគ្រប់គ្រង ដឹកនាំ និងផ្ទេរនូវចំណេះដឹងជូនដល់យើងខ្ញុំជា និស្សិត។

យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ធូណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោក លោកស្រីសាស្ត្រាចារ្យ បានផ្តល់ នូវពុទ្ធិ ការអប់រំ និងសីលធម៌យ៉ាងល្អថ្លៃថ្លា មកដល់យើងខ្ញុំបាទទាំងពីរក្នុងរយៈពេល ៤ ឆ្នាំកន្លងមកនេះ។

ជាពិសេស លោកសាស្ត្រាចារ្យ **បណ្ឌិត ហាប់ ផល្លី** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំផ្ទាល់។ សូមថ្លែងអំណរគុណចំពោះការកែតម្រូវ ណែនាំ ផ្តល់មតិយោបល់ និងពន្យល់យ៉ាងម៉ត់ចត់លើចំណុចខ្វះខាតដែលក្រុមរបស់យើងខ្ញុំមាន។ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលមានលោកគ្រូជា សាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំទាំងពីរសូមបួងសួងដល់បារមីនៃវត្ថុស័ក្តសិទ្ធិទាំងពួងនៅលើលោកនេះ មេត្តាថែរក្សាអ្នកមានគុណទាំងពីរ ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ មន្ត្រីការិយាល័យស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសលោកសាស្ត្រាចារ្យ **បណ្ឌិត ហាប់ ផល្លី** សូមឱ្យជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើនគ្រប់ពេលវេលា។

# **អារម្ភកថា**

ការសិក្សាថ្នាក់បរិញ្ញាបត្ររយៈពេល ៤ ឆ្នាំ ត្រូវបានបញ្ចប់ដោយការសរសេរសារណាមួយនេះ។ សារណាបញ្ចប់ការសិក្សានេះ គឺជាការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ ដោយបានដាក់បញ្ចូលនូវចំណេះដឹង និងបទពិសោធន៍ដែលពួកយើងមាននៅក្នុងការសិក្សាកន្លងមក។

ដូច្នេះ ក្នុងនាមយើងខ្ញុំជានិស្សិត ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំ និងសរសេរសារណាមួយនេះឡើងដោយក្រោមប្រធានបទស្តីពី **ក្របខណ្ឌគតិយុត្តនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា** ដើម្បីធ្វើការសិក្សាស្វែងយល់បន្ថែមទៀតទាក់ទងនឹងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ជាការពិតណាស់ សង្គមជាតិនាពេលបច្ចុប្បន្ន កំពុងវិវត្តទៅមុខជាលំដាប់ ការអភិវឌ្ឍបានឈានទៅមុខជារឿយៗ ដូច្នេះ ការសិក្សាស្វែងយល់ក៏ត្រូវស្របតាមបរិបទនៃការអភិវឌ្ឍផងដែរ។

សារណាមួយនេះ ពឹងផ្អែកទៅលើការបកស្រាយដោយយោងទៅលើ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្ររបស់ថ្នាក់ដឹកនាំ ការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យ និងឯកសារនានាដែលពាក់ព័ន្ធក្នុងវិស័យពាណិជ្ជកម្ម។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការស្រាវជ្រាវមួយនេះនឹងអាចផ្តល់នូវការយល់ដឹងបន្ថែមទៀតដល់និស្សិតគ្រប់រូប និងអ្នកអាន ដើម្បីមាននូវមូលដ្ឋានពាក់ព័ន្ធនឹងប្រធានបទ និងចំពោះអ្នកមានបំណងចង់សិក្សាស្វែងយល់បន្ថែមទៅលើវិស័យនេះ។

ក្រុមយើងខ្ញុំសូមអភ័យទោស ចំពោះចំណុចខ្វះខាត និងការធ្វេសប្រហែសនានា លើពាក្យពេចន៍ អត្ថន័យ អក្ខរាវិរុទ្ធ និងទម្រង់ ដែលកើតមានឡើងដោយកំហុសអចេតនា។ ព្រោះការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំមានគំនិតចង់ឱ្យអ្នកអានទទួលបាននូវពុទ្ធិបន្ថែមតែប៉ុណ្ណោះ។ ជាចុងក្រោយ យើងខ្ញុំទទួលនូវរាល់មតិយោបល់រិះគន់នានា ដើម្បីស្ថាបនាឱ្យការស្រាវជ្រាវកាន់តែមានភាពល្អប្រសើរ ត្រឹមត្រូវ និងប្រកបដោយអត្ថន័យជ្រាលជ្រៅបន្ថែមទៀត។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២៤

# មាតិកា

ទំព័រ

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ... ១
៣. គោលបំណងនៃការស្រាវជ្រាវ ... ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ... ២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ... ២
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ... ២

## ជំពូកទី ១
## សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

១.១ ដំណើរវិវត្តន៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ... ៤
១.១.១ ការកកើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ... ៤
១.១.២ បច្ចុប្បន្នភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ... ៦
១.១.៣ និយមន័យ ... ៧
១.២ ភាពខុសគ្នារវាងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការធ្វើពាណិជ្ជកម្មទូទៅ ... ៨
១.៣ ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ... ១០

## ជំពូកទី ២
## ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

២.១ ដំណើរការនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ... ១៥
២.១.១ ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ... ១៥
២.១.១.១ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា ... ១៦

២.១.១.២ អានុភាពគតិយុត្តនៃកិច្ចសន្យា....................................................................................១៨

២.១.១.៣ ហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក...................................................................................១៩

២.១.២ ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិ ..................................................២១

២.១.២.១ ការជ្រើសរើសទំនិញ.............................................................................................. ២៥

២.១.២.២ ការបញ្ជាទិញ ...................................................................................................... ២៥

២.១.២.៣ ការទូទាត់ប្រាក់...................................................................................................... ២៥

២.១.២.៤ ការដឹកជញ្ជូន និងទទួលទំនិញ..........................................................................................២៧

២.១.៣ ការបង្កើតកិច្ចសន្យាតាមរយៈអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........................................................................................................................................២៩

២.១.៣.១ និយមន័យ និងតួនាទីរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ....................................................................................................................................... ២៩

២.១.៣.២ កាតព្វកិច្ចនៃការស្នើសុំអាជ្ញាបណ្ណ......................................................................................... ៣០

២.១.៣.៣ កាតព្វកិច្ចនៃការទទួលខុសត្រូវ និងមិនទទួលខុសត្រូវ ............................................... ៣១

២.២ កាតព្វកិច្ចពន្ធចំពោះការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា................................. ៣៣

២.២.១ កាតព្វកិច្ចរបស់អ្នកជាប់ពន្ធនិវាសនជន ................................................................................. ៣៣

២.២.២ កាតព្វកិច្ចរបស់អ្នកជាប់ពន្ធអនិវាសនជន...................................................................................៣៤

២.២.៣ មធ្យោបាយនៃការទូទាត់ប្រាក់ពន្ធ ..........................................................................................៣៥

២.៣ កិច្ចការពារអ្នកប្រើប្រាស់ចំពោះការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក... ..............................៣៦

២.៣.១ កិច្ចការពារចំពោះការរងនូវការអនុវត្តសកម្មភាពទុច្ចរិត................................................ ៣៧

២.៣.២ កិច្ចការពារចំពោះការលក់ទំនិញដោយភ្ជាប់សេចក្តីបរិយាយមិនពិត.................................៣៨

២.៣.៣ កិច្ចការពារលើទិន្នន័យរបស់អ្នកប្រើប្រាស់ ................................................................ ៤០

# ជំពូកទី៣
## បញ្ហាប្រឈម និងដំណោះស្រាយចំពោះការធ្វើពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រូនិក


៣.១ បញ្ហាប្រឈម............................................................................................................................៤២

៣.១.១ បញ្ហាទំនុកចិត្តរបស់ភាគីនៃការធ្វើពាណិជ្ជកម្ម................................................................៤២

៣.១.២ ភាពកង្វះខាតនៃផ្នែកច្បាប់ និងផ្នែកបច្ចេកវិទ្យា................................................................៤៣

៣.១.៣ បទល្មើសកើតមានឡើងតាមរយៈការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ......................... ៤៥

៣.២ ដំណោះស្រាយចំពោះបញ្ហាប្រឈម ...................................................................................... ៤៦

៣.២.១ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ..............................................................................៤៧

៣.២.២ ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា.........................................................................៤៧

៣.២.៣ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ..................................................................... ៤៨

៣.២.៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម................................................................ ៤៩

៣.២.៥ តុលាការ.......................................................................................................................៤៩

**សេចក្តីសន្និដ្ឋាន**...........................................................................................................................៥០

**អនុសាសន៍**....................................................................................................................................៥១


**គន្ថនិទ្ទេស**

# បញ្ជីរូប

**ទំព័រ**

រូបទី ១៖ ការកើតឡើងនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្ម ដំណាក់កាលទី៣។ ..... ៥
រូបទី ២៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករទៅពាណិជ្ជករ។ ..... ១១
រូបទី ៣៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករទៅអ្នកប្រើប្រាស់។ ..... ១២
រូបទី ៤៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅអ្នកប្រើប្រាស់។ ..... ១២
រូបទី ៥៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅអ្នកប្រើប្រាស់។ ..... ១៣
រូបទី ៦៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅពាណិជ្ជករ។ ..... ១៣
រូបទី ៧៖ ការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រព័ន្ធស្វ័យប្រវត្តិ។ ..... ២៨
រូបទី ៨៖ ទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាធ្វើឡើងដោយប្រព័ន្ធស្វ័យប្រវត្តិ។ ..... ២៨

# បញ្ជីតារាង

**ទំព័រ**

តារាង១៖ ការប្រៀបធៀបរវាងការបង្កើតកិច្ចសន្យាទូទៅ និងកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក..........១៦

តារាង២៖ បទល្មើស និងការផ្តន្ទាទោសក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក..........៤៥

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ចាប់ពីឆ្នាំ១៩៩៣ ប្រទេសកម្ពុជាអនុវត្តតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។[១] កំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជាពឹងផ្អែកលើវិស័យនានាដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ និងជាពិសេសគឺ វិស័យពាណិជ្ជកម្ម។ បច្ចុប្បន្ន ការវិវត្តចេះតែចម្រើនទៅមុខដោយវិស័យពាណិជ្ជកម្មបានដើរតួយ៉ាងសំខាន់ដែលជាចរន្តឈាមមួយខ្វះពុំបាននៃសេដ្ឋកិច្ចជាតិ ហើយការធ្វើពាណិជ្ជកម្មបានវិវត្តដោយធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិកដែលជាបរិបទថ្មី និងទំនើបមួយ។ តាមរយៈកំណើននៃការប្រើប្រាស់និងការប្រកបរបរពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាហេតុអ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាគួរមានច្បាប់គាំពារ។ ហេតុដូច្នេះ ទើបរដ្ឋសភាបានយកចិត្តទុកដាក់លើការបង្កើតច្បាប់ និងរាជរដ្ឋាភិបាលបានចេញលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេសនៅឆ្នាំ២០១៩ រដ្ឋសភាបានអនុម័តច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយនាំឱ្យការយល់ដឹងអំពីក្របខណ្ឌគតិយុត្តក្នុងការគាំពារការធ្វើពាណិជ្ជកម្មនេះពិតជាសំខាន់។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយហេតុប្រទេសកម្ពុជាមានការអភិវឌ្ឍ និងរីកចម្រើនទៅមុខបានយ៉ាងឆាប់រហ័សលើការធ្វើពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស ព្រមទាំងផ្នែកបច្ចេកវិទ្យាកាន់តែរីកចម្រើនថែមទៀត ហេតុដូច្នេះទើបមានការបង្កើតថ្មីនូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលនាំឱ្យមានការចោទជាសំណួរថា៖

- តើអ្វីជាការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក?
- តើកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងអានុភាពនៃកិច្ចសន្យានោះប្រព្រឹត្តឡើងយ៉ាងដូចម្ដេច?
- តើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមាននូវបញ្ហាប្រឈមអ្វីខ្លះដល់អ្នកប្រើប្រាស់? ជាពិសេស តើបញ្ហាប្រឈមទាំងនោះមានដំណោះស្រាយយ៉ាងដូចម្ដេច?

[១] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, មាត្រា៥៦។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការជ្រើសរើសប្រធានបទមួយនេះ មកធ្វើការសិក្សាស្រាវជ្រាវដោយមានគោលបំណងដូចជា៖

- ស្វែងយល់ឱ្យកាន់តែច្បាស់ទាក់ទងនឹងទិដ្ឋភាពច្បាប់នៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- ស្វែងយល់ពីការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- ស្វែងយល់ពីភាពខុសគ្នារវាងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការធ្វើពាណិជ្ជកម្មទូទៅ។
- ស្វែងយល់ពីការធ្វើប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។
- ស្វែងយល់ពីកិច្ចការការពារចំពោះអ្នកប្រើប្រាស់។
- ស្វែងយល់ពីបញ្ហាប្រឈមដែលអាចជួបប្រទះ ព្រមទាំងដំណោះស្រាយចំពោះបញ្ហាទាំងនោះ។
- ចងក្រងទុកជាឯកសារសម្រាប់ជាស្នាដៃ និងជាផលប្រយោជន៍ដល់និស្សិតជំនាន់ក្រោយ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សារណានេះ មានដែនកំណត់គ្របដណ្តប់ទៅលើទិដ្ឋភាពច្បាប់ និងការអនុវត្តទាក់ទងនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កិច្ចសិក្សាស្រាវជ្រាវនេះមានវិសាលភាពក្នុងក្របខណ្ឌនៃច្បាប់កម្ពុជាដែលមានដូចជា ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេច។ល។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ ត្រូវបានប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវដូចខាងក្រោម៖

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារួមមាន អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេច។
- ការវិភាគលើឯកសារច្បាប់ ការស្រាវជ្រាវជាភាសាបរទេស និងប្រភពព័ត៌មានផ្សេងៗតាមរយៈប្រព័ន្ធអនឡាញ។
- ការណែនាំពីសាស្ត្រាចារ្យ មន្ត្រីរាជរដ្ឋាភិបាល អ្នកអនុវត្តច្បាប់ និងឯកសារគតិយុត្តនានា។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ ចែកចេញជា ៣ ជំពូក។ ជំពូកទី ១ បង្ហាញអំពី សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយលើកឡើងអំពីការវិវត្តចាប់តាំងពីពេលកកើតរហូតដល់បច្ចុប្បន្ន និងយល់ដឹងកាន់តែច្បាស់រវាងភាពខុសគ្នានៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងពាណិជ្ជកម្មទូទៅ។

ជាបន្ទាប់ ជំពូកទី ២ ពិភាក្សាអំពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយក្នុងនោះការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាចំណុចដែលចាំបាច់ត្រូវយល់ដឹង និងកាតព្វកិច្ចផ្សេងៗក្រោយការបង្កើតកិច្ចសន្យាដែលមានដូចជាកាតព្វកិច្ចពន្ធ និងកិច្ចការពារអ្នកប្រើប្រាស់ជាដើម។ ជាចុងក្រោយ ជំពូកទី ៣ លើកឡើងអំពីបញ្ហាប្រឈមដែលអ្នកប្រើប្រាស់អាចជួបប្រទះ ព្រមទាំងដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនោះ។

# ជំពូកទី ១
# សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

# ជំពូកទី ១
# សញ្ញាណទូទៅនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការរីកចម្រើនជាលំដាប់នៃបច្ចេកវិទ្យា តម្រូវឱ្យមានការបង្កើតថ្មីជាបន្តបន្ទាប់។ ក្នុងពេលបច្ចុប្បន្ន ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការរីកចម្រើន និងអភិវឌ្ឍយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់ ហើយដើម្បីស្របតាមការរីកចម្រើននេះ ការបង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគ្រប់គ្រងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺជាការចាំបាច់។ ទន្ទឹមជាមួយគ្នានេះ ដើម្បីជៀសផុតពីហានិភ័យផ្សេងៗក្នុងពេលធ្វើពាណិជ្ជកម្មដោយប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ការយល់ដឹងអំពីសញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺជាការចាំបាច់ និងមានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់។

ជំពូកទី ១ នេះ លើកឡើងអំពីដំណើរវិវត្តន៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចាប់ពីពេលកកើតរហូតដល់ពេលបច្ចុប្បន្ន និងស្វែងយល់ឱ្យកាន់តែច្បាស់បន្ថែមទៀតថា អ្វីជាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១.១) ភាពខុសគ្នានៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការធ្វើពាណិជ្ជកម្មទូទៅ (១.២) និងទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមានចំនួន ៧ ទម្រង់ (១.៣)។

## ១.១ ដំណើរវិវត្តន៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### ១.១.១ ការកកើតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការលេចឡើងនូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនទើបតែកើតមាននាពេលថ្មីៗនេះ ឬក្នុងសម័យទំនើបនេះទេ។ ជាក់ស្តែងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានតាំងពីអំឡុងទសវត្សរ៍ទី៧០ មកម្ល៉េះ ដែលនាពេលនោះគឺជាការអនុវត្តក្នុងសម័យបដិវត្តន៍ឧស្សាហកម្មលើកទី៣ ឬហៅថា បដិវត្តន៍ឌីជីថលដែលជាការផ្លាស់ប្តូរពីមេកានិច និងអេនណាលឡុកអេឡិចត្រូនិកទៅជាប្រព័ន្ធឌីជីថលអេឡិចត្រូនិក។[២] សម័យបដិវត្តន៍ឧស្សាហកម្មលើកទី ៣ ជាសម័យនៃការប្រើប្រាស់ដំបូងនូវប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិកក្នុងការធ្វើកិច្ចសន្យាជួញដូរនានា និងកុំព្យូទ័រទាំងអស់អាចមានលទ្ធភាពក្នុងការផ្លាស់ប្តូរ និងផ្ទេរទិន្នន័យព័ត៌មាន។[៣] នាទសវត្សរ៍ទី៨០ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការវិវត្តបន្តិចម្តងៗ រហូតដល់ចុងសតវត្សរ៍ទី២០ និងដើមសតវត្សរ៍ទី២១ ទើបមានសន្ទុះនៃការប្រើប្រាស់យ៉ាងខ្លាំង និងគួរឱ្យកត់សម្គាល់នៅជុំវិញពិភពលោក[៤] ហើយការកើនឡើងនេះបានបញ្ជ្រាបចូល

[២] គុណ រក្សា, "តើឧស្សាហកម្ម៤.0គឺជាអ្វី? បដិវត្តឧស្សាហកម្មមានអ្វីខ្លះ?", Medium, ១១ មករា ២០២៣។

[៣] ចិន ស្រីពេជ្រ, "ការវិវត្តនៃបដិវត្តឧស្សាហកម្ម", The Seed គ្រាប់ពូជកម្ពុជា, ១៨ តុលា ២០២១។

[៤] តាន់ មន្នីវិសាល, "បដិវត្តន៍ឧស្សាហកម្មទី ៥", អត្ថបទជំនួយស្មារតី, 0៤ មិថុនា ២០១៩។

មកក្នុងប្រទេសកម្ពុជាបន្តិចម្តងៗ រហូតដល់មានការប្រើប្រាស់ច្រើនពីសំណាក់ប្រជាជនកម្ពុជាមកទល់ពេលបច្ចុប្បន្ន។[៥]

ដើម្បីបង្កើនទំនុកចិត្តរបស់អ្នកប្រើប្រាស់ អង្គការអន្តរជាតិនានាបានខិតខំបង្កើតនូវសន្ធិសញ្ញាអន្តរជាតិ និងច្បាប់គំរូ ដើម្បីលើកកម្ពស់ភាពច្បាស់លាស់ ជាក់លាក់ និងស្ថិរភាពក្នុងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ។[៦] គណៈកម្មការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ ដែលជាភាសាអង់គ្លេសហៅថា UNITED NATIONS COMMISSION ON INTERNATIONAL TRADE LAW "UNCITRAL" បានបង្កើតនូវច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលភាសាអង់គ្លេសហៅថា UNCITRAL MODEL LAW ON ELECTRONIC COMMERCE។[៧] ច្បាប់គំរូនេះ គឺជាផ្នែកមួយក្នុងការជួយសម្រួល បង្កើនភាពស្របគ្នាក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអន្តរជាតិ និងការពារអ្នកប្រើប្រាស់ផងដែរ។ នៅពេលដែលប្រទេសកម្ពុជាមិនទាន់មានច្បាប់គ្រប់គ្រងលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រទេសកម្ពុជាបានយកច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះមកប្រើប្រាស់ និងអនុវត្ត។

រូបទី១៖ ការកើតឡើងនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៣[៨]




[៥] International Trade Administration, *Cambodia- Country Commercial Guide* [ការណែនាំផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា], eCommerce, ២០២៤។

[៦] Alan Davidson, *Social Media And Electronic Commerce Law* [ប្រព័ន្ធផ្សព្វផ្សាយសង្គម និងច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក], (Australia: Cambridge University Press, Second Edition, ២០១៦), ១៥៦។

[៧] United Nations Commission on International Trade Law, *UNCITRAL Model Law on Electronic Commerce* [ច្បាប់គំរូស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក], ១២ មិថុនា ១៩៩៦។

[៨] https://www.velatia.com/en/blog/what-are-the-keys-to-industry-៤-0/ (ចូលទស្សនាថ្ងៃទី២១ ឧសភា ២០២៤)។

### ១.១.២ បច្ចុប្បន្នភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ស្ថានភាពនៃការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ ដោយក្នុងនោះកត្តាជំរុញមួយដ៏សំខាន់នៃកំណើនពាណិជ្ជកម្មនៅប្រទេសកម្ពុជា គឺការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើពាណិជ្ជកម្ម។ ជាពិសេស ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅប្រទេសកម្ពុជា មានកំណើនអ្នកប្រើប្រាស់យ៉ាងច្រើននាអំឡុងពេលជម្ងឺកូវីត ១៩ ដោយការជួញដូរ និងការបង្កើតកិច្ចសន្យានានាភាគច្រើនសុទ្ធសឹងតែធ្វើតាមប្រព័ន្ធអេឡិចត្រូនិកទាំងអស់។ ដោយយោងតាមការវាស់ស្ទង់បានឱ្យឃើញថា ក្នុងចំណោមមនុស្ស ១០០% មានបុរសចំនួន ៦៦% និងនារីចំនួន ៣៤% ដែលបានប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកទូទាំងប្រទេសកម្ពុជាដើម្បីធ្វើពាណិជ្ជកម្ម និងទិញទំនិញតាមប្រព័ន្ធអនឡាញយ៉ាងតិច ១ ដង ក្នុងរយៈពេល ១ ខែ។[៩]

នាពេលបច្ចុប្បន្ន ពិភពលោកកំពុងស្ថិតក្នុងបដិវត្តន៍ឧស្សាហកម្ម ៤.០ ជាហេតុប្រទេសកម្ពុជាត្រូវធ្វើការពង្រឹង និងបង្កើននូវប្រសិទ្ធិភាពក្នុងការអភិវឌ្ឍប្រទេសជាតិ និងកសាងសេដ្ឋកិច្ចរបស់ប្រទេសឱ្យកាន់តែប្រសើរឡើង។ ប្រទេសកម្ពុជា បានផ្តោតសំខាន់លើធាតុសំខាន់ៗមួយចំនួនដូចជា (១) មូលដ្ឋានឌីជីថលសំដៅដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល (២) ក្របខណ្ឌច្បាប់ដើម្បីបង្កើននូវភាពជឿជាក់ដល់ការប្រើប្រាស់ទំនិញ សេវាឌីជីថល ការធ្វើធុរកិច្ចឌីជីថល និងគ្រប់គ្រងសន្តិសុខសាយប័រ (៣) មូលធនមនុស្សដែលសំដៅដល់ការសាបព្រោះចំណេះដឹងផ្នែកឌីជីថល (៤) ការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសាធារណៈ និង (៥) ការជំរុញដល់ការធ្វើធុរកិច្ចឌីជីថល។[១០] លើសពីនេះ នៅក្នុងនីតិកាលថ្មីនៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ ដែលប្រទេសកម្ពុជាត្រូវសម្រេចតាម។ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ បានកំណត់យកនូវអាទិភាពគន្លឹះចំនួន ៥ សំខាន់ៗមានដូចជា បញ្ចកោណទី១ គឺការអភិវឌ្ឍមូលធនមនុស្ស។ បញ្ចកោណទី២ គឺការធ្វើពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង។ បញ្ចកោណទី៣ គឺការអភិវឌ្ឍវិស័យឯកជន និងការងារ។ បញ្ចកោណទី៤ គឺការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន។ បញ្ចកោណទី៥ គឺការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ ហើយនៅក្នុងបញ្ចកោណទី៥ នេះ ក៏មាននូវធាតុផ្សំនៃពាណិជ្ជកម្ម

[៩] Profitence (Cambodia) Co., Ltd, *E-Commerce in Cambodia* [ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា], Survey Methodology, ២០២៣។

[១០] ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, *ក្របខណ្ឌ និងគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥* (ភ្នំពេញ, ២០២១), ១២។

តាមប្រព័ន្ធអេឡិចត្រូនិកដែលរាជរដ្ឋាភិបាលបានកំណត់យកជាអាទិភាព ក្នុងការជំរុញដល់ការអភិវឌ្ឍប្រទេសជាតិ។[១១]

ដោយយល់ឃើញថា ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចូលរួមយ៉ាងសកម្មសម្រាប់សេដ្ឋកិច្ចរបស់ប្រទេស ធ្វើឱ្យបរិយាកាសនៃការធ្វើពាណិជ្ជកម្មកាន់តែល្អប្រសើរ ជាពិសេសដើម្បីដើរស្របនឹងបដិវត្តន៍ឧស្សាហកម្ម៤.០ ប្រទេសកម្ពុជាបានបង្កើត ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ការបង្កើតច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះឡើង មានគោលបំណងបង្កើតភាពប្រាកដប្រជាមួយផ្នែកគតិយុត្ត ក្នុងប្រតិបត្តិការផ្នែកពាណិជ្ជកម្ម និងផ្នែករដ្ឋប្បវេណីតាមប្រព័ន្ធអេឡិចត្រូនិក និងដើម្បីគ្រប់គ្រងរាល់ការធ្វើពាណិជ្ជកម្ម ដោយផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការធ្វើទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក។[១២] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានវិសាលភាពទាំងក្នុងដែនដី និងក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ បើទោះបីជាមាន ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយ ក៏ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនបានឃ្លាតឆ្ងាយពី ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ឡើយ ដោយក្រមរដ្ឋប្បវេណីនៅតែជាធាតុគោល និងជាជំនួយដែលជួយបំពេញនូវចំណុចខ្វះខាត ឬចំណុចដែលច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនបានចែង ដើម្បីឱ្យការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដំណើរការបានរលូនទៅមុខ និងស្ថិតក្រោមការគាំពារដោយច្បាប់។

### ១.១.៣ និយមន័យ

ចំពោះវាក្យសព្ទ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់ឱ្យនិយមន័យផ្សេងៗគ្នា ប៉ុន្តែអត្ថន័យ ឬធាតុដើមនៃនិយមន័យមិនមានភាពខុសគ្នាទាំងស្រុង ឬខុសដាច់ស្រឡះពីគ្នានោះទេ។ នៅក្នុងក្របខណ្ឌអន្តរជាតិ ដោយយោងតាមអង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ ដែលហៅកាត់ជាភាសាអង់គ្លេសថា UNESCO បានឱ្យនិយមន័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកថាជាវិធីសាស្ត្រនៃការបញ្ជាទិញ និងការផ្តល់ផលិតផលដោយមធ្យោបាយអេឡិចត្រូនិក ដូចជាតាមរយៈប្រព័ន្ធអ៊ិនធឺណិត ឬបណ្តាញដែលសម្របសម្រួលដោយកំព្យូទ័រផ្សេងទៀត។[១៣] បន្ថែមពីនេះ ដោយយោង

[១១] រដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១*, (ភ្នំពេញ, ២០២៣), ៣២-៣៥។

[១២] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា១។

[១៣] UNESCO, *Electronic commerce* [ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក], ២០១២។

តាមអង្គការពាណិជ្ជកម្មពិភពលោក បានឱ្យនិយមន័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកថាជា ការផលិត ការចែកចាយ ការធ្វើទីផ្សារ ការលក់ ឬការផ្តល់នូវទំនិញ ឬសេវាដោយតាមមធ្យោបាយអេឡិចត្រូនិក។[១៤]

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៃព្រះរាជាណាចក្រកម្ពុជា ឱ្យនិយមន័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់ "សកម្មភាពទិញលក់ ជួល ផ្លាស់ប្តូរ ទំនិញ ឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពផ្នែកពាណិជ្ជកម្ម និងផ្នែករដ្ឋប្បវេណី ព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក។"[១៥] គួរបញ្ជាក់ថាពាក្យ អេឡិចត្រូនិក ដែលជាពាក្យគ្រឹះមួយ សំដៅដល់"អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានដូចជា ចរន្តអគ្គិសនី ឌីជីថល ម៉ាញេទិច អុបទិក ជីវមាត្រ អេឡិចត្រូគីមី វ៉ាយអឺឡេស អេឡិចត្រូម៉ាញេទិក ឬ បច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។"[១៦]

## ១.២ ភាពខុសគ្នារវាងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការធ្វើពាណិជ្ជកម្មទូទៅ

បន្ទាប់ពីបានយល់ដឹងពីនិយមន័យនៃវាក្យសព្ទ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកខាងលើរួចមក ចំណុចដែលត្រូវលើកឡើងបន្ទាប់គឺ តើរបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងរបបពាណិជ្ជកម្មទូទៅមានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ។

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការធ្វើពាណិជ្ជកម្មទូទៅ មិនមានលក្ខណៈខុសគ្នាច្រើនទេ ពោលគឺការបង្កើតកិច្ចសន្យាមិនខុសពីការបង្កើតកិច្ចសន្យាផ្សេងៗនោះទេ ដែលតម្រូវឱ្យមានមូលដ្ឋានគ្រឹះនៃលក្ខខណ្ឌច្បាប់ក្នុងការបង្កើត ដើម្បីឱ្យកិច្ចសន្យានោះអាចកើតមានឡើង និងអាចអនុវត្តបាន។ ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មគ្រប់ប្រភេទត្រូវមានការធ្វើសំណើ និងស្វីការរបស់ភាគីនៃកិច្ចសន្យាជាការចាំបាច់ ដោយជាគោលការណ៍ គ្មានកិច្ចសន្យាណាមួយបង្កើតឡើងដោយមិនមានសំណើ និងស្វីការនោះទេ។ ដូច្នេះ នេះគឺជាគោលការណ៍ទូទៅមួយនៃកិច្ចសន្យាដែលគ្រប់កិច្ចសន្យាសុទ្ធសឹងតែមានសំណើ និងស្វីការ រួមទាំងកិច្ចសន្យានៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។

[១៤] Yasmin Ismail, *E-commerce in the World trade Organization* [ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក], ២០២០, ២។

[១៥] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, ឧបសម្ព័ន្ធ។

[១៦] ដដែល, ឧបសម្ព័ន្ធ។

ដោយឡែកលក្ខណៈខុសគ្នារវាងការធ្វើពាណិជ្ជកម្មតាមបែបទាំងពីរនេះ មានដូចជា (១) ទម្រង់នៃកិច្ចសន្យា (២) ភាពងាយស្រួលដល់អ្នកប្រើប្រាស់ (៣) ការទទួលបានព័ត៌មាន (៤) ការចំណាយពេលវេលា និងថវិកា និង (៥) ភាពទំនើបនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ទីមួយ ទាក់ទងនឹងទម្រង់នៃកិច្ចសន្យា។ ទម្រង់នៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកខុសពីទម្រង់នៃកិច្ចសន្យាពាណិជ្ជកម្មទូទៅត្រង់មានប្រព័ន្ធបច្ចេកវិទ្យាចូលរួម ពោលគឺការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យា ដើម្បីបង្កើតកិច្ចសន្យាដែលអាចធ្វើឡើងតាមរយៈគេហទំព័រ ថ្នាលឌីជីថល កំព្យូទ័រ និងទូរស័ព្ទជាដើម។ ហើយនេះខុសពីទម្រង់នៃកិច្ចសន្យាដែលបង្កើតក្នុងការធ្វើពាណិជ្ជកម្មទូទៅ ដោយតម្រូវឱ្យភាគីត្រូវសរសេរជាលាយលក្ខណ៍អក្សរ ឬជាលិខិតស្នាមដោយផ្ទាល់ដៃ និងត្រូវធ្វើនៅចំពោះមុខភាគី ឬពាណិជ្ជករ។

ទីពីរ ទាក់ទងនឹងភាពងាយស្រួលដល់អ្នកប្រើប្រាស់។ ជាទូទៅ ការធ្វើពាណិជ្ជកម្មមិនមែនសំដៅតែទៅលើការធ្វើពាណិជ្ជកម្មក្នុងស្រុកនោះទេ វាអាចជាទំនាក់ទំនងរវាងប្រទេសមួយទៅកាន់ប្រទេសមួយទៀត ឬរវាងទ្វីបមួយទៅកាន់ទ្វីបមួយផ្សេងទៀត។ ដូច្នេះប្រសិនបើ ការធ្វើពាណិជ្ជកម្មដែលតម្រូវឱ្យភាគីមកជួបគ្នាដោយផ្ទាល់ដើម្បីបង្កើតកិច្ចសន្យានោះ គឺប្រាកដជាមានការលំបាក។ បើទោះបីជាភាគីនៃការធ្វើពាណិជ្ជកម្មស្ថិតនៅក្នុងប្រទេសមួយដូចគ្នាក៏ដោយ ក៏នៅតែមិនមានភាពងាយស្រួល ដើម្បីមកជួបគ្នាដោយផ្ទាល់ដែរ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនេះ ដើម្បីធ្វើពាណិជ្ជកម្មភាគីអាចស្ថិតនៅទីតាំងខុសគ្នានិងឆ្ងាយគ្នាប៉ុណ្ណា ក៏នៅតែអាចធ្វើការទំនាក់ទំនងគ្នា និងបង្កើតកិច្ចសន្យាបានដែរ ដែលនេះជាភាពងាយស្រួលមួយដ៏ធំសម្រាប់អ្នកប្រើប្រាស់ និងពាណិជ្ជករ។

ទីបី ទាក់ទងនឹងការទទួលបានព័ត៌មាន។ អ្នកលក់ និងអ្នកទិញក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺងាយស្រួលក្នុងការទទួលបានព័ត៌មាននៅលើទីផ្សារ ដោយអ្នកទិញមានភាពងាយស្រួលក្នុងការមើលនូវព័ត៌មានផ្សេងៗចំពោះផលិតផល ឬទំនិញដែលខ្លួនចង់ទិញ។ មិនតែប៉ុណ្ណោះ ពេលខ្លះផលិតផល ឬទំនិញនោះ មាននូវការវាយតម្លៃ ឬមតិយោបល់របស់អ្នកប្រើប្រាស់មុនៗទៀតផង ដែលធ្វើឱ្យអ្នកទិញងាយស្រួលក្នុងការគិតពិចារណា និងសម្រេចចិត្តក្នុងការទិញទំនិញថែមមួយកម្រិតទៀត។ ចំណែកអ្នកលក់វិញ ងាយស្រួលទទួលបានព័ត៌មានផ្សេងៗទាំងការដាក់សំណើទិញនានា ការវាយតម្លៃដែលខ្លួនអាចយកមកពិចារណា និងការពង្រឹងនូវចំណុចខ្វះខាតរបស់ខ្លួនឡើងវិញបាន។ ការទទួលបានព័ត៌មាននេះ មានភាពងាយស្រួល និងទទួលបានលឿនជាងការធ្វើពាណិជ្ជកម្មទូទៅ ដែលពេលខ្លះព័ត៌មានដែលអ្នកទិញធ្វើការវាយតម្លៃទៅកាន់អ្នកលក់ដោយផ្ទាល់ អាចបង្កឱ្យមានការមិនសប្បាយចិត្ត ឬកើតជាជម្លោះរវាងគ្នា។

ទីបួន ទាក់ទងនឹងការចំណាយពេលវេលា និងថវិកា។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជួយសន្សំនូវការចំណាយផ្សេងៗដូចជា ថវិកា និងពេលវេលាជាងការធ្វើពាណិជ្ជកម្មទូទៅ។ ការទិញលក់ទំនិញនៅក្នុងការធ្វើពាណិជ្ជកម្មទូទៅ អ្នកលក់ និងអ្នកទិញតែងជួបគ្នាដោយផ្ទាល់ និងបង្កើតកិច្ចសន្យាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរស្របតាមឆន្ទៈរបស់ភាគីនៃកិច្ចសន្យា។ ការធ្វើកិច្ចសន្យាបែបនេះ មានលក្ខណៈជាក់លាក់ និងភាគីមានទំនុកចិត្តខ្ពស់ ប៉ុន្តែភាគីនៃកិច្ចសន្យាត្រូវចំណាយពេលវេលា និងថវិកាសម្រាប់ការមកជួបដោយផ្ទាល់ ដែលនេះជាហេតុធ្វើឱ្យមានការលំបាកចំពោះការធ្វើពាណិជ្ជកម្ម។ ផ្ទុយទៅវិញ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចធ្វើនៅពេលណាក៏បាន ទាំងពេលថ្ងៃ និងពេលយប់ដោយមិនចាំបាច់ធ្វើការរង់ចាំនោះទេ ដែលនេះជាការពន្លឿនដល់សេចក្តីត្រូវការ និងការធ្វើជំនួញផ្សេងៗរបស់អ្នកប្រើប្រាស់។

ទីប្រាំ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺមានភាពទំនើបដែលដើរស្របតាមបដិវត្តន៍ឧស្សាហកម្ម ៤.០។ ដូចបានរៀបរាប់ផ្នែកខាងលើរួចមក នាពេលបច្ចុប្បន្ននៅក្នុងសង្គម និងពិភពលោកកំពុងស្ថិតក្នុងបដិវត្តន៍ឧស្សាហកម្ម ៤.០ ដែលប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យា ឬមូលដ្ឋានឌីជីថលក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ ដូចនេះ ដើម្បីដើរស្របទៅនឹងបរិបទសង្គមនាពេលបច្ចុប្បន្ន អ្នកប្រើប្រាស់ចាំបាច់ផ្លាស់ប្តូរមកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកក្នុងការធ្វើពាណិជ្ជកម្ម ទើបការធ្វើពាណិជ្ជកម្មនោះមានភាពប្រសើរឡើង។

## ១.៣ ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការប្រាស្រ័យទាក់ទងក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានលក្ខណៈខុសគ្នាទៅតាមទម្រង់នីមួយៗ ដោយទម្រង់ទាំងនោះមាន ៧ ទម្រង់ដូចជា ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករទៅពាណិជ្ជករ ពាណិជ្ជករទៅអ្នកប្រើប្រាស់ អ្នកប្រើប្រាស់ទៅអ្នកប្រើប្រាស់ អ្នកប្រើប្រាស់ទៅពាណិជ្ជករ រដ្ឋាភិបាលទៅពាណិជ្ជករ រដ្ឋាភិបាលទៅរដ្ឋាភិបាល និងអ្នកប្រើប្រាស់ទៅរដ្ឋាភិបាល។[១៧]

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករទៅពាណិជ្ជករមានន័យថា ពាណិជ្ជករដែលជាអ្នកផ្គត់ផ្គង់ទំនិញឬសេវា បានប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិក ឬថ្នាលបច្ចេកវិទ្យាក្នុងការបង្កើតសំណើ រួចពាណិជ្ជករផ្សេងទៀតបានផ្តល់នូវស្នើការចំពោះសំណើនោះ។ ជាឧទាហរណ៍ ក្រុមហ៊ុន ក ជាអ្នកបោះដុំសម្ភារៈអគ្គិសនី ដោយក្រុមហ៊ុន ក បានដាក់លក់សម្ភារៈរបស់ខ្លួនក្នុងគេហទំព័រ។ ក្រុមហ៊ុន ខ

[១៧] អាន សុវឌ្ឍនា, "ទម្រង់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក" (បទបង្ហាញសម្រាប់និស្សិតបរិញ្ញាបត្រនីតិសាស្ត្រសិក្សាជាភាសាអង់គ្លេស, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៤ តុលា ២០២៣)។

ជាក្រុមហ៊ុនដែលលក់សម្ភារៈអគ្គិសនីតាមបណ្តាខេត្ត ក៏បានទិញសម្ភារៈពីក្រុមហ៊ុន ក តាមរយៈគេហទំព័រនោះដើម្បីយកមកលក់បន្តនៅខេត្តរបស់ខ្លួន។ នេះ គឺជាការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករមួយទៅកាន់ពាណិជ្ជករមួយទៀត។

រូបទី២៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករទៅពាណិជ្ជករ[១៨]




ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករទៅអ្នកប្រើប្រាស់មានន័យថា ពាណិជ្ជករដែលជាអ្នកផ្គត់ទំនិញ ឬសេវា បានប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិក ឬថ្នាលបច្ចេកវិទ្យាក្នុងការផ្គត់ផ្គង់ដោយផ្ទាល់ទៅកាន់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់ អាចជ្រើសរើសនូវទំនិញដែលខ្លួនពេញចិត្តក្នុងគេហទំព័រ ឬកន្លែងដាក់សំណើទិញ រួចបង់ប្រាក់ចំពោះទំនិញ និងថ្លៃសេវាដឹកជញ្ជូនជាការស្រេច។ ទំនាក់ទំនងរវាងពាណិជ្ជករនិងអ្នកប្រើប្រាស់នេះ អាចមានជាការទាក់ទងដោយផ្ទាល់ពីអ្នកលក់ទៅកាន់អ្នកទិញ និងការទាក់ទងដោយមានអន្តរការី ឬអ្នកផ្តល់សេវាពាណិជ្ជកម្មចូលរួមផងដែរ។

[១៨] https://www.equinoxitsol.com/blog/top-១២-ecommerce-business-models-in-២០២១/ (ចូលទស្សនាថ្ងៃទី២១ ឧសភា ២០២៤)។

រូបទី៣៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីពាណិជ្ជករទៅអ្នកប្រើប្រាស់[១៩]



ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅអ្នកប្រើប្រាស់មានន័យថា អ្នកប្រើប្រាស់បានធ្វើការប្រើប្រាស់នូវថ្នាលបច្ចេកវិទ្យា ដែលជួយក្នុងការលក់នូវទំនិញ ឬទ្រព្យសម្បត្តិរបស់ខ្លួននៅក្នុងថ្នាលបច្ចេកវិទ្យានោះ។ បន្ទាប់មក អ្នកផ្សេងទៀតដែលត្រូវជាអ្នកប្រើប្រាស់ដូចគ្នា អាចមើលលើថ្នាលដែលបានដាក់លក់នោះបាន និងអាចធ្វើសំណើដើម្បីទិញទំនិញ។ ការប្រាស្រ័យទាក់ទងបែបនេះគឺជាការទិញលក់ពីបុគ្គលទៅបុគ្គលដែលជាអ្នកប្រើប្រាស់ដូចគ្នា។

រូបទី៤៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅអ្នកប្រើប្រាស់[២០]



[១៩] https://www.equinoxitsol.com/blog/top-១២-ecommerce-business-models-in-២០២១/ (ចូលទស្សនាថ្ងៃទី២១ ឧសភា ២០២៤)។

[២០] https://www.equinoxitsol.com/blog/top-១២-ecommerce-business-models-in-២០២១/ (ចូលទស្សនាថ្ងៃទី២១ ឧសភា ២០២៤)។

រូបទី៥៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅអ្នកប្រើប្រាស់[២១]




ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅពាណិជ្ជករ មានន័យថា អ្នកប្រើប្រាស់បានប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិក ក្នុងការបង្ហាញ និងដាក់លក់ផលិតផលរបស់ខ្លួនទៅកាន់ពាណិជ្ជករ។ ជាឧទាហរណ៍ កសិករបានដាំដើមស្វាយជាច្រើនដើមនៅដីចំការរបស់ខ្លួន។ លុះដល់រដូវប្រមូលផល កសិករបានដាក់លក់ស្វាយរបស់ខ្លួនតាមរយៈគេហទំព័ររបស់ខ្លួន រួចមានក្រុមហ៊ុនដំណាប់ស្វាយបានទិញផ្លែស្វាយពីកសិករ ដើម្បីយកទៅធ្វើដំណាប់ស្វាយផងដែរ។ នេះគឺជាទំនាក់ទំនងនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាងអ្នកប្រើប្រាស់ទៅកាន់ពាណិជ្ជករ។

រូបទី៦៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅពាណិជ្ជករ[២២]




[២១] https://www.mca.co.in/images/E-commerce_Business_Models.pdf (ចូលទស្សនាថ្ងៃទី២១ ឧសភា ២០២៤)។
[២២] https://www.equinoxitsol.com/blog/top-១២-ecommerce-business-models-in-២០២១/ (ចូលទស្សនាថ្ងៃទី២១ ឧសភា ២០២៤)។

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីរដ្ឋាភិបាលទៅកាន់អ្នកប្រើប្រាស់ អាចបង្ហាញតាមរយៈរាជរដ្ឋាភិបាលប្រើប្រាស់នូវគេហទំព័រ ដែលជាវិធីសាស្ត្រក្នុងការចែករំលែកទៅកាន់ប្រជាជន។ គេហទំព័រទាំងនោះ អាចជាការផ្តល់នូវសេវាក្នុងការចុះបញ្ជីក្រុមហ៊ុន ការប្រកាសពន្ធ និងបង់ពន្ធផ្សេងៗ ដោយគោលដៅសំខាន់ គឺដើម្បីសម្រួលដល់ការលំបាករបស់ប្រជាជនដែលជាអ្នកប្រើប្រាស់ ដោយមិនចាំបាច់ទៅកាន់ទីកន្លែងដោយផ្ទាល់ ចំណេញពេលវេលា និងថវិកាផងដែរ។ នៅក្នុងប្រទេសកម្ពុជា សកម្មភាពដែលរាជរដ្ឋាភិបាល បានទទួលស្គាល់នូវទំនាក់ទំនងអេឡិចត្រូនិក ដោយបានឆ្លុះបញ្ចាំងក្នុងការប្រើប្រាស់ ឬការធ្វើសកម្មភាពប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក ហើយសកម្មភាព និងប្រតិបត្តិការទាំងនោះរួមមានៈ[២៣]

ក-ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើត ឬរក្សាទុកឯកសារ។

ខ-ការចេញអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត។

គ-ការកំណត់មធ្យោបាយ និងរបៀបក្នុងការទូទាត់ប្រាក់។ ឬ

ឃ-សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

នៅក្នុងវិស័យរវាងរាជរដ្ឋាភិបាល និងរាជរដ្ឋាភិបាលក៏មានការប្រើប្រាស់នូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយការប្រើប្រាស់នោះក្នុងគោលដៅចែករំលែកនូវទិន្នន័យ និងព័ត៌មានផ្សេងៗក្នុងការពង្រឹងទំនាក់ទំនងឱ្យកាន់តែល្អ និងឆាប់រហ័ស។ ចំណែកចុងក្រោយ គឺការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីអ្នកប្រើប្រាស់ទៅរដ្ឋាភិបាល ដោយអ្នកប្រើប្រាស់អាចប្រើប្រាស់សេវារបស់រដ្ឋក្នុងការធ្វើប្រតិបត្តិការបង់ប្រាក់ និងអាចផ្តល់ជាមតិយោបល់ផ្សេងៗទៅកាន់រដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។ ជាឧទាហរណ៍ ប្រជាជនបង់ពន្ធជូនរដ្ឋតាមរយៈប្រព័ន្ធអនឡាញ ឬនៅក្នុងថ្នាលរបស់អគ្គនាយកដ្ឋានពន្ធដារជាដើម។

[២៣] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា៣៤។

# ជំពូកទី ២
# ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

# ជំពូកទី ២
# ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ជំពូកទី ២ នេះ ពិភាក្សាអំពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយលើកយកនូវលក្ខខណ្ឌនានាដែលច្បាប់តម្រូវ ដើម្បីការប្រព្រឹត្តទៅនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយភាពរលូនទៅមុខ។ នៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលណាក៏ដោយមិនអាចបដិសេធ ឬ អះអាងក្នុងការមិនទទួលស្គាល់លើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះទេ ប្រសិនបើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការបង្កើតឡើងត្រឹមត្រូវ ហើយស្របតាមលក្ខខណ្ឌដែលច្បាប់បានតម្រូវ។[២៤] ចំពោះសុពលភាព អានុភាពគតិយុត្ត និងការអនុវត្ត មានតម្លៃដូចនឹងការធ្វើពាណិជ្ជកម្មទូទៅ។

ហេតុដូច្នេះ ក្នុងជំពូកនេះមានផ្នែកចំនួន ៣ សំខាន់ៗដូចជា ដំណើរការនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយទាក់ទងនឹងការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធស្វ័យប្រវត្តិ ព្រមទាំងការបង្កើតតាមរយៈបុគ្គលដែលជាអ្នកសម្របសម្រួលក្នុងប្រតិបត្តិការពាណិជ្ជកម្ម (២.១) កាតព្វកិច្ចពន្ធដោយយោងតាមច្បាប់កម្ពុជាចំពោះការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (២.២) និង កិច្ចការពារអ្នកប្រើប្រាស់ក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (២.៣)។

## ២.១ ដំណើរការនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### ២.១.១ ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការធ្វើពាណិជ្ជកម្ម គឺជាទំនាក់ទំនងរវាងបុគ្គល និង បុគ្គលដែលអាចជាការសន្យាគ្នាក្នុងការអនុវត្តនូវសកម្មភាពណាមួយក្នុងជំនួញ។ គួរបញ្ជាក់ថា ដោយយោងតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានករណីលើកលែងដោយមិនអាចអនុវត្តទៅលើប្រភេទកម្មវត្ថុនៃកិច្ចសន្យាមួយចំនួនដូចជា កិច្ចសន្យាដែលមានកម្មវត្ថុទាក់ទងនឹងការប្រគល់សិទ្ធិ ការបង្កើត ឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែតម្រូវមតកសាសន៍ ឬបញ្ហាទាក់ទិននឹងសន្តតិកម្ម កិច្ចសន្យាទាក់ទងនឹងអចលនវត្ថុដោយមានជាការលក់ ការផ្ទេរ ឬបោះបង់សិទ្ធិជាដើម និងកិច្ចសន្យាជាការផ្ទេរអចលនវត្ថុ ឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ។[២៥] ជាឧទាហរណ៍ កិច្ចសន្យាលក់ទិញផ្ទះ មិនអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិកបាននោះទេ បើទោះបីជាមាននូវការព្រមព្រៀងដោយពិតប្រាកដ មាន

[២៤] ដដែល, មាត្រា១៣។
[២៥] ដដែល, មាត្រា៣។

ហត្ថលេខាអេឡិចត្រូនិក និងការទូទាត់ប្រាក់រួចហើយក៏ដោយ។ ព្រោះកិច្ចសន្យាដែលទាក់ទងនឹងការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុបែបនេះ តម្រូវធ្វើជាលិខិតយថាភូតស្របតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។[២៦]

ខាងក្រោមនេះ ជាលក្ខណៈខុសគ្នារវាងការបង្កើតកិច្ចសន្យាទូទៅ និងការបង្កើតកិច្ចសន្យាតាមរយៈប្រព័ន្ធអេឡិចត្រូនិក៖

តារាង១៖ ការប្រៀបធៀបរវាងការបង្កើតកិច្ចសន្យាទូទៅ និងកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក

| **កិច្ចសន្យាទូទៅ** | **កិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក** |
|---|---|
| • កិច្ចសន្យាបង្កើតឡើងដោយសរសេរលើក្រដាស។ | • កិច្ចសន្យាបង្កើតឡើងដោយឌីជីថល។ |
| • ភាគីនៃកិច្ចសន្យា គឺមានវត្តមានជួបដោយផ្ទាល់ក្នុងពេលបង្កើតកិច្ចសន្យា។ | • ភាគីនៃកិច្ចសន្យា មិនចាំបាច់មានវត្តមានជួបដោយផ្ទាល់នាពេលបង្កើតកិច្ចសន្យានោះទេ។ |
| • ការធ្វើប្រតិបត្តិការមានតម្លៃខ្ពស់។ | • ការធ្វើប្រតិបត្តិការមានតម្លៃទាប។ |
| • ប្រើប្រាស់ពេលវេលាច្រើន។ | • សន្សំពេលវេលាបានច្រើន។ |
| • ភាពប្រថុយប្រថានមានកម្រិតទាប មានសុវត្ថិភាពខ្ពស់។ | • មានភាពប្រថុយប្រថានខ្ពស់ ទាក់ទងនឹងទំនុកចិត្ត និងទំនិញឬសេវា។ |

### ២.១.១.១ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា

កិច្ចសន្យាមួយមានសុពលភាព អានុភាព និងអាចអនុវត្តបាន លុះត្រាតែកិច្ចសន្យានោះស្របតាមលក្ខខណ្ឌច្បាប់។ លក្ខខណ្ឌនៃកិច្ចសន្យាដែលបង្កើតឡើងតាមប្រព័ន្ធអេឡិចត្រូនិក មិនមានភាពខុសគ្នាខ្លាំងពីការបង្កើតកិច្ចសន្យាទូទៅនោះទេ ដែលតម្រូវធ្វើឡើងដោយមានភាគីទាំងសងខាងព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ ឬគំរាមកំហែងណាមួយ។ កិច្ចសន្យាដែលបង្កើតឡើងត្រូវមានកម្ម

[២៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៣៦។

វត្ថុច្បាស់លាស់ ហើយកម្មវត្ថុនៃកិច្ចសន្យានោះមិនផ្ទុយនឹងច្បាប់ ឬទំនៀមទម្លាប់ល្អក្នុងសង្គម កម្មវត្ថុនៃកិច្ចសន្យាអាចធ្វើទៅបាន ឬមានលទ្ធភាពក្នុងការសម្រេច និងភាគីទាំងសងខាងមានឆន្ទៈក្នុងការបង្កើតកិច្ចសន្យានោះយ៉ាងពិតប្រាកដផងដែរ។ ចំពោះសំណើ និងស្វីការនៅក្នុងកិច្ចសន្យាដែលបង្កើតឡើងតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយអេឡិចត្រូនិក ហើយអានុភាពគតិយុត្ត និងភាពអាចអនុវត្តបាននៃកិច្ចសន្យានឹងកើតមាននៅពេលសំណើ និងស្វីការត្រូវគ្នា។[២៧]

ការយល់អត្ថន័យច្បាស់ពីពាក្យសំណើ មានសារៈសំខាន់ក្នុងការពិភាក្សា។ សំណើ សំដៅលើ "ការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។"[២៨] មានន័យថា អាចចាត់ទុកថាជាសំណើបាន លុះត្រាតែការស្នើសុំបង្កើតកិច្ចសន្យាកើតឡើងពីឆន្ទៈរបស់អ្នកស្នើសុំពិតប្រាកដ និងអ្នកស្នើសុំបានបង្ហាញច្បាស់ពីឆន្ទៈក្នុងការបង្កើតកិច្ចសន្យារបស់ខ្លួន។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានបញ្ញត្តិទាក់ទងនឹងសំណើផងដែរ ដោយការស្នើសុំចុះកិច្ចសន្យានឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ច នៅពេលមានស្វីការពីភាគីម្ខាងទៀត។[២៩] គួរកត់សម្គាល់ថា ការបង្កើតសំណើ និងការអញ្ជើញឱ្យធ្វើសំណើ មានលក្ខណៈខុសគ្នាដោយការអញ្ជើញឱ្យធ្វើសំណើ មិនមែនជាលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យានោះទេ មានតែការធ្វើសំណើប៉ុណ្ណោះដែលជាលក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យា។[៣០] ការអញ្ជើញឱ្យធ្វើសំណើ ត្រឹមតែជាការទាក់ទាញឱ្យអ្នកដទៃមកធ្វើសំណើវិញប៉ុណ្ណោះ។ ជាឧទាហរណ៍ ការដាក់បង្ហាញតម្លៃលើទំនិញនៅក្នុងគេហទំព័រ ដើម្បីឱ្យអ្នកទិញអាចធ្វើការបញ្ជាទិញ ដោយនោះមិនមែនជាសំណើទេ។[៣១]

សំណើ មានអានុភាពនៅពេលដែលសំណើបានដល់ភាគីម្ខាងទៀត។ ក្នុងន័យនេះមិនមែនមានន័យថា សំណើនឹងមានអានុភាពលុះត្រាតែអ្នកទទួលបានទទួលព័ត៌មាននោះទេ ដោយគ្រាន់តែពេលព័ត៌មានបានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកធ្វើ ចាត់ទុកថាសំណើមាន

[២៧] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា១២។
[២៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៣៧។
[២៩] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា១៦។
[៣០] ដដែល។
[៣១] Fukuoka Fumie និង Umemoto Yumi, "បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី", ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។

អានុភាពហើយ។ បន្ថែមពីនេះ នៅពេលដែលព័ត៌មានត្រូវបានផ្ញើចេញពីទីតាំងណាមួយក៏ដោយ ក៏ច្បាប់បានសន្មតថាព័ត៌មាននោះត្រូវបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ។[៣២]

ចំណែកស្វីការ សំដៅលើ “ការសំដែងឆន្ទៈដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះ សំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។”[៣៣] មានន័យថា ចាត់ទុកថាជាស្វីការលុះត្រាតែជាការឆ្លើយតបនឹងសំណើដែលអ្នកផ្ញើបានដាក់ស្នើសុំ ដែលអាចជាការយល់ព្រម ឬបដិសេធការស្នើសុំ។ ក្នុងករណីដែលការឆ្លើយតបនោះមិនមែនជាការយល់ព្រមនឹងសំណើទាំងស្រុង ឬមានការជជែកកែប្រែបន្តទៀត ដែលនោះមិនមែនជាស្វីការទេ ហើយកិច្ចសន្យាក៏មិនទាន់បង្កើតឡើងដែរ។ ស្វីការមានអានុភាពនៅពេលដែលស្វីការបានដល់អ្នកស្នើ។[៣៤] ជាឧទាហរណ៍ លោក ក ជាអ្នកលក់កាតាបតាមអនឡាញដែលលោកតែងតែបង្ហោះនូវកាតាបដែលមានម៉ូតថ្មីៗជារៀងរាល់ថ្ងៃ។ លោក ខ បានឃើញការបង្ហោះរបស់លោក ក ពេលនោះលោក ខ ក៏បានផ្ញើសារទៅកាន់លោក ក ដោយសួរនូវតម្លៃ និងប្រាប់ទៅកាន់លោក ក ថាខ្លួនទិញកាតាបមួយនោះ។ សកម្មភាពនៃការប្រាប់របស់លោក ខ ទៅកាន់លោក ក បែបនេះគឺជាការបង្ហាញឆន្ទៈរបស់អ្នកផ្ញើដែលជាសំណើក្នុងនៅក្នុងកិច្ចសន្យា។ ជាការឆ្លើយតប លោក ក បានយល់ព្រមនឹងដាក់អីវ៉ាន់ជូនលោក ខ ដែលនេះជាស្វីការក្នុងកិច្ចសន្យា។ លោក ក និងលោក ខ បានបង្កើតសំណើ និងស្វីការដោយប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិក។ ដូចនេះ កិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានបង្កើតឡើង។

#### ២.១.១.២ អានុភាពគតិយុត្តនៃកិច្ចសន្យា

បន្ទាប់ពីកិច្ចសន្យាបានបង្កើតឡើងស្របតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ កិច្ចសន្យានឹងមានអានុភាពចំពោះគូភាគី ដោយអ្នកផ្ញើសំណើ និងអ្នកផ្តល់ស្វីការក្នុងទំនាក់ទំនងអេឡិចត្រូនិក មិនអាចត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬ សេចក្តីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។[៣៥] អានុភាពគតិយុត្តនៃកិច្ចសន្យាបានផ្តល់នូវសិទ្ធិ និងករណីយកិច្ចដល់គូភាគីនៃកិច្ចសន្យា ដោយអានុភាពដែលកើតឡើងចំពោះភាគីនៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏មិនខុសប្លែកពីអានុភាពកិច្ចសន្យាទូទៅនោះទេ។ ប្រសិនបើក្នុងកិច្ចសន្យាលក់ទិញ អ្នកផ្គត់ផ្គង់ទំនិញ ឬ សេវាមានករណីយកិច្ចមួយចំនួនចំពោះអ្នកទិញ ចំណែកឯអ្នកទិញមានករណីយកិច្ចមួយចំនួនចំពោះអ្នកលក់

[៣២] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា១៥។
[៣៣] ដដែល, ឧបសម្ព័ន្ធ។
[៣៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៣៧។
[៣៥] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា១៣។

វិញដូចគ្នា។ ករណីយកិច្ចរបស់អ្នកលក់ និងអ្នកទិញ មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកលក់មានករណីយកិច្ចដូចជា ត្រូវពន្យល់ឱ្យបានច្បាស់លាស់ទាក់ទងនឹងកម្មវត្ថុនៃការលក់ទិញ ករណីយកិច្ចផ្ទេរទ្រព្យសម្បត្តិនោះទៅកាន់អ្នកទិញ និងករណីយកិច្ចនៅក្នុងការធានាជាដើម។[៣៦] ចំណែកអ្នកទិញ ក្រោយពីកិច្ចសន្យាមានអានុភាព អ្នកទិញមានករណីយកិច្ចត្រូវបង់ថ្លៃជាប្រាក់ដែលសន្យានោះ និងទទួលវត្ថុដែលខ្លួនបានទិញ។[៣៧]

### ២.១.១.៣ ហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក

កិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពេលខ្លះចាំបាច់តម្រូវឱ្យភ្ជាប់មកជាមួយនូវហត្ថលេខារបស់ភាគីនៃកិច្ចសន្យា ដោយការចុះ ឬការភ្ជាប់ហត្ថលេខា ក៏ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ ហត្ថលេខាអេឡិចត្រូនិក សំដៅដល់រាល់ហត្ថលេខាដែលបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលរួមមានដូចជា ហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និងហត្ថលេខាដទៃទៀត។[៣៨] ហត្ថលេខាអេឡិចត្រូនិក ត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ដូចជា ហត្ថលេខាអេឡិចត្រូនិកត្រូវផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់ ហត្ថលេខានោះអាចកំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី មានការបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី មានការបញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខា និងហត្ថលេខាត្រូវបញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់។[៣៩]

ម្យ៉ាងវិញទៀត ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព គឺជាហត្ថលេខាអេឡិចត្រូនិកដែលចុះដោយបុគ្គលពាក់ព័ន្ធ និងបុគ្គលដែលមានឆន្ទៈពិតប្រាកដក្នុងការចុះហត្ថលេខា ឬ បានឯកភាពលើកំណត់ត្រាអេឡិចត្រូនិកនោះ។[៤០] ការតម្រូវឱ្យមានការបញ្ជាក់បែបនេះ គឺដើម្បីឱ្យមានភាពកាន់តែច្បាស់លាស់ និងជាក់លាក់ពីអត្តសញ្ញាណរបស់ភាគីផងដែរ ដែលនេះដូចគ្នានឹងការចុះហត្ថលេខាដោយដៃផ្ទាល់លើលិខិតជាលាយលក្ខណ៍អក្សរ។

ចំពោះអានុភាពនៃហត្ថលេខាអេឡិចត្រូនិក គឺមិនមានការកម្រិតណាមួយនោះទេ ដោយឱ្យតែហត្ថលេខាអេឡិចត្រូនិកបានប្រើប្រាស់ស្របច្បាប់នៅក្នុងសកម្មភាពពាណិជ្ជកម្ម និងសកម្មភាពរដ្ឋប្បវេណី

[៣៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៥២៩-៥៣១។
[៣៧] ដដែល, មាត្រា៥៥៤-៥៥៥។
[៣៨] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, ឧបសម្ព័ន្ធ។
[៣៩] ដដែល, មាត្រា២០។
[៤០] ដដែល, មាត្រា២១។

ហើយបង្កើតឡើងស្របតាមច្បាប់កំណត់ ហត្ថលេខាអេឡិចត្រូនិកនឹងមានអានុភាព ដែលអាចអះអាងបានជាភស្តុតាងជឿជាក់មួយបាន។ យោងតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមានការចែងជាក់លាក់អំពីសកម្មភាព ដែលមិនអាចប្រើប្រាស់នូវហត្ថលេខាអេឡិចត្រូនិកបាននោះទេ។ ប៉ុន្តែអាចបកស្រាយបានថា ការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិកនេះ អាចប្រើប្រាស់លើរាល់សកម្មភាពពាណិជ្ជកម្ម និងសកម្មភាពរដ្ឋប្បវេណី ឯកសារ និងប្រតិបត្តិការផ្សេងៗ លើកលែងតែ (១) ការបង្កើត និងការអនុវត្តនូវលិខិតតំណាងដោយអាណត្តិ (២) ការបង្កើត និងការចុះហត្ថលេខាលើលិខិតបណ្តាំ និង លិខិតផ្សេងៗទាក់ទងនឹងមតកសាសន៍ (៣) កិច្ចសន្យានានាទាក់ទងនឹងការលក់ ការផ្ទេរ ការបោះបង់សិទ្ធិ និងផលប្រយោជន៍ទាក់ទងនឹងអចលនវត្ថុ (៤) ករណីផ្សេងៗទៀតដែលមានចែងក្នុងអនុក្រឹត្យដែលបានកំណត់មិនអាចធ្វើទៅបាន។[៤១] ការគ្រប់គ្រងចំពោះនីតិវិធីសុវត្ថិភាពលើហត្ថលេខាអេឡិចត្រូនិកនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។[៤២]

ក្រៅពីច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រទេសកម្ពុជាក៏មាននូវអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល ដែលបានបង្កើតឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីគ្រប់គ្រង និងជំរុញការប្រើប្រាស់ហត្ថលេខាឌីជីថលនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែមានសុវត្ថិភាព និងប្រសិទ្ធិភាពខ្ពស់។[៤៣] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនបានបញ្ជាក់ថាហត្ថលេខាអេឡិចត្រូនិក គឺដូចគ្នានឹងហត្ថលេខាឌីជីថលឬអត់នោះទេ។ ប៉ុន្តែដោយយោងតាមនិយមន័យនៃហត្ថលេខាអេឡិចត្រូនិកក្រោមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺហត្ថលេខាឌីជីថលចាត់ចូលជាប្រភេទមួយនៃហត្ថលេខាអេឡិចត្រូនិក។[៤៤] ហត្ថលេខាឌីជីថល សំដៅដល់ទិន្នន័យដែលភ្ជាប់នឹងសារអេឡិចត្រូនិក ដើម្បីបញ្ជាក់អត្តសញ្ញាណនៃហត្ថលេខីឌីជីថល និង ផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិចត្រូនិក ដែលហត្ថលេខីបានចុះហត្ថលេខា។[៤៥] ដើម្បីចាត់ទុកបានជាហត្ថលេខាឌីជីថល ត្រូវមានលក្ខខណ្ឌដូចជាបញ្ជាក់អត្តសញ្ញាណរបស់ហត្ថលេខីឌីជីថលដោយត្រឹមត្រូវ និងជាក់លាក់ បញ្ជាក់អំពីស្ថានភាពដើមនៃសារអេឡិចត្រូនិក បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខាឌីជីថល និង ចំណុចផ្សេងទៀតដែលកំណត់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។[៤៦] បន្ថែមពីនេះ សារអេឡិចត្រូនិក

[៤១] Nadarashnaraj Sargunaraj, "Electronic & Digital Signatures in ASEAN" [ហត្ថលេខាអេឡិចត្រូនិកនិងហត្ថលេខាឌីជីថលនៅក្នុងអាស៊ាន], (២០២០): ២។

[៤២] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា២៣។

[៤៣] អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦ អនក្រ.បក, ២៩ ធ្នូ ២០១៧, មាត្រា១។

[៤៤] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, ឧបសម្ព័ន្ធ។

[៤៥] អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦ អនក្រ.បក, ២៩ ធ្នូ ២០១៧, មាត្រា៤។

[៤៦] ដដែល, មាត្រា៩។

ដែលមានភ្ជាប់ហត្ថលេខាឌីជីថលបញ្ជាក់ដោយវិញ្ញាតធរហត្ថលេខាឌីជីថល មានតម្លៃគតិយុត្តស្មើនឹងលិខិតលាយលក្ខណ៍អក្សរ។[៤៧] ហត្ថលេខាឌីជីថលដែលមានបញ្ជាក់ដោយវិញ្ញាតធរហត្ថលេខាឌីជីថល មានន័យថា បុគ្គលដែលប្រើប្រាស់នូវហត្ថលេខាឌីជីថល បានស្នើសុំនូវវិញ្ញាបនបត្រហត្ថលេខាឌីជីថល ដែលវិញ្ញាតធរហត្ថលេខាឌីជីថល ជាអ្នកផ្ដល់ឱ្យបន្ទាប់ពីបុគ្គលស្នើសុំនោះបានបំពេញគ្រប់លក្ខខណ្ឌដែលបានតម្រូវ។[៤៨] វិញ្ញាតធរហត្ថលេខាឌីជីថល គឺជាបុគ្គលដែលទទួលបានវិញ្ញាតកម្មហត្ថលេខាឌីជីថល ពីអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (អ.ប.គ.ព) ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ)។[៤៩] បុគ្គលដែលប្រើប្រាស់នូវហត្ថលេខាឌីជីថលតម្រូវឱ្យមានវិញ្ញាបនបត្រហត្ថលេខាឌីជីថល ព្រោះវាបានកំណត់អត្តសញ្ញាណច្បាស់លាស់របស់កម្មសិទ្ធិករនៃហត្ថលេខាឌីជីថល ដែលជាការការពារដោយមានសុវត្ថិភាពមួយសម្រាប់អ្នកប្រើប្រាស់។

ទោះបីជា ហត្ថលេខាឌីជីថល ត្រូវបានចាត់ទុកថាជាប្រភេទមួយនៃហត្ថលេខាអេឡិចត្រូនិក ប៉ុន្តែបើធ្វើការប្រៀបធៀបហត្ថលេខាទាំងពីរនេះមានលក្ខណៈខុសគ្នាមួយចំនួន ដោយហត្ថលេខាអេឡិចត្រូនិក មិនតម្រូវឱ្យមានការបញ្ជាក់ពីអាជ្ញាធរណាមួយក្នុងការប្រើប្រាស់នោះទេ មិនដូចនឹងហត្ថលេខាឌីជីថលដែលត្រូវមានការបញ្ជាក់ពីវិញ្ញាតធរហត្ថលេខាឌីជីថល ទើបសារនោះមានតម្លៃគតិយុត្តស្មើនឹងលិខិតជាលាយលក្ខណ៍អក្សរ។ ហត្ថលេខាឌីជីថល មានភាពតឹងរឹងជាងហត្ថលេខាអេឡិចត្រូនិកដោយហត្ថលេខាអេឡិចត្រូនិក អាចជាការប្រើប្រាស់ឈ្មោះធម្មតា ការប្រើប្រាស់រូបភាព សញ្ញានៅក្នុងឯកសារ ឬ ជាការចុចលើប៊ូតុងខ្ញុំយល់ព្រម "I accept" ឬ "Accept Cookie"។[៥០] ចំណែកហត្ថលេខាឌីជីថលត្រូវតែជាហត្ថលេខា ឬ ស្នាមមេដៃតាមប្រព័ន្ធអេឡិចត្រូនិកដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ច្បាស់លាស់។[៥១]

### ២.១.២ ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិ

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមួយបែបទៀត គឺការបង្កើតកិច្ចសន្យាដោយប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ។ កិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិ គឺជាកិច្ចសន្យាដែលបង្កើតឡើងរវាង

[៤៧] ដដែល, មាត្រា១០។

[៤៨] ដដែល, មាត្រា២៥។

[៤៩] ដដែល, មាត្រា១៤។

[៥០] Michelle Davidson, "Everything You Need to Know about Electronic and Digital singatures" [អ្វីដែលអ្នកត្រូវយល់ដឹងអំពីហត្ថលេខាអេឡិចត្រូនិកនិងហត្ថលេខាឌីជីថល], GlobalSign Blog, ១១ កក្កដា ២០២៣។

[៥១] Emudhra Trust Delivered, "What is the difference between a Digital Signature and an Electronic Signature?" [តើអ្វីជាភាពខុសគ្នារវាងហត្ថលេខាឌីជីថល និងហត្ថលេខាអេឡិចត្រូនិក] ។

រូបវន្តបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយ ឬជាមួយប្រព័ន្ធស្វ័យប្រវត្តិនៃបុគ្គលផ្សេងទៀត។ ក្នុងលក្ខណៈអន្តរជាតិ អ្នកប្រើប្រាស់តែងតែជួបប្រទះនូវការបង្កើតកិច្ចសន្យាជាមួយប្រព័ន្ធស្វ័យប្រវត្តិបែបនេះ ដែលមានលក្ខណៈដូចជា Click-wrap agreements, Shrink-wrap agreements និង Browse-wrape/Web-wrape agreements ជាដើម។ ជាឧទាហរណ៍ នៅពេលប្រើប្រាស់នូវប្រព័ន្ធអ៊ិនធឺណិត ឬហ្គូហ្គល Google អ្នកប្រើប្រាស់តែងតែបានឃើញនូវឃ្លាថា ខ្ញុំយល់ព្រម "I AGREE" ឬ ខ្ញុំមិនយល់ព្រម "I DISAGREE" ទៅលើលក្ខខណ្ឌណាមួយដែលត្រូវបានបង្ហាញ។ ការបង្ហាញបែបនេះ តម្រូវឱ្យមានការចុចជ្រើសរើសនូវជម្រើសទាំងពីរប្រភេទ ដែលជាប្រភេទមួយនៃកិច្ចសន្យាតាមប្រព័ន្ធស្វ័យប្រវត្តិដោយត្រូវចុចនូវឃ្លាថា ខ្ញុំយល់ព្រម "I AGREE" ទើបអាចប្រើប្រាស់ ឬ ទាញយកនូវកម្មវិធី ឬ ព័ត៌មានពីគេហទំព័រនោះបាន។ ម្យ៉ាងវិញទៀត វាអាចជាប្រភេទនៃការព្រមព្រៀង ដែលតែងតែឃើញបន្ទាប់ពី បានទិញ ឬទាញយកនូវអាជ្ញាបណ្ណសម្រាប់ប្រើប្រាស់លើឧបករណ៍ដែលបានបិទក្នុងកញ្ចប់អេឡិចត្រូនិកដែលជាភាសាអង់គ្លេសហៅថា Material inside the package និងកម្មវិធីផ្សេងៗទៀតដែលជាភាសាអង់គ្លេសហៅថា Software។ ដោយលក្ខខណ្ឌនឹងលោតចេញមក នៅពេលដែលបើកកម្មវិធីនោះ ដើម្បីឱ្យអ្នកប្រើប្រាស់អាន និងចុចទទួលយកមុននឹងអាចចូលទៅប្រើប្រាស់កម្មវិធីបាន។

ចំពោះកិច្ចសន្យាបង្កើតឡើងដោយប្រព័ន្ធស្វ័យប្រវត្តិមួយទៀត គឺជាការចូលទៅកាន់គេហទំព័រ ឬកម្មវិធីដែលបានរៀបចំដោយបុគ្គលផ្គត់ផ្គង់ទំនិញឬសេវា រួចជ្រើសរើសទំនិញ និងធ្វើការទូទាត់ប្រាក់ជាការស្រេច។ ជាឧទាហរណ៍ ការធ្វើប្រតិបត្តិការបញ្ជាទិញទំនិញពីគេហទំព័រ ឬកម្មវិធីណាមួយ ដូចជា Amazon, Alibaba, Taobao, Lazada។ល។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបែបនេះ ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តម្រូវឱ្យធ្វើការស្នើសុំនូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណសម្រាប់ប្រកបអាជីវកម្មនេះ។ ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ មានកំណត់ដូចជា (១) ទីកន្លែងដាក់ពាក្យស្នើសុំ (២) បែបបទ និងនីតិវិធីនៃការស្នើសុំ និង (៣) សុពលភាពនៃការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ។ រូបវន្តបុគ្គលដែលនឹងប្រកបអាជីវកម្ម ធ្វើប្រតិបត្តិការ ឬសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវស្នើសុំលិខិតអនុញ្ញាត ចំណែកឯនីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសត្រូវស្នើសុំអាជ្ញាបណ្ណ។ ដោយទីតាំងនៃការស្នើសុំលិខិតអនុញ្ញាត និងអាជ្ញាបណ្ណ គឺនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

ចំពោះបែបបទ ឬឯកសារតម្រូវក្នុងការចុះបញ្ជីដើម្បីទទួលបានលិខិតអនុញ្ញាតមានដូចជា៖[៥២]

សម្រាប់រូបវន្តបុគ្គល៖

- លិខិតអនុញ្ញាតប្រកបអាជីវកម្មចេញដោយអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត
- ប័ណ្ណប៉ាតង់ (ប្រសិនបើមាន)
- អត្តសញ្ញាណបណ្ណដែលនៅមានសុពលភាពរបស់បុគ្គលស្នើសុំ
- រូបថត ៤x៦ របស់រូបវន្តបុគ្គល ដែលថតមិនលើសពី ៣ខែមុន
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

សម្រាប់សហគ្រាសឯកបុគ្គល៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ប័ណ្ណប៉ាតង់
- មានគណនីនៅគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ប្រសិនបើមាន)
- បុគ្គលស្នើសុំត្រូវបំពេញពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

បន្ទាប់ពីបានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតរួចរាល់ មន្ត្រីត្រួតពិនិត្យនឹងធ្វើការឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ នៃថ្ងៃធ្វើការ។ ដោយឡែក ចំពោះនីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសវិញត្រូវមានបែបបទ និងឯកសារដែលតម្រូវដូចជា៖[៥៣]

[៥២] ប្រកាសស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ២៤០ ព.ណចបព.ប្រក, ៩ តុលា ២០២០, ប្រការ៣។

[៥៣] ដដែល, ប្រការ៥។

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- ប័ណ្ណប៉ាតង់
- វិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ឯកសារអំពីមធ្យោបាយទូទាត់ប្រាក់ផ្តល់ ដោយបុគ្គលផ្តល់សេវាទូទាត់ ដែលទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា
- ឯកសារគំរូអាជីវកម្ម (Business Model) និងទម្រង់កិច្ចការពារអ្នកប្រើប្រាស់ សម្រាប់ការធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក
- គំរូកិច្ចសន្យារវាងអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវការព័ត៌មាន អប្បបរមាសម្រាប់(អន្តរការី)
- បុគ្គលស្នើសុំត្រូវបំពេញព័ត៌មាន នៅក្នុងតារាងនៃពាក្យស្នើសុំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

បន្ទាប់ពីបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណរួចរាល់ មន្ត្រីត្រួតពិនិត្យនឹងធ្វើការឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃនៃថ្ងៃធ្វើការ។ ចំពោះសុពលភាពនៃលិខិតអនុញ្ញាតរបស់រូបវន្តបុគ្គល និងសហគ្រាសឯកបុគ្គលមានរយៈពេល ២ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម។ ចំណែកនីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេស អាជ្ញាបណ្ណមានសុពលភាពរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់អាជ្ញាបណ្ណដោយក្រសួងពាណិជ្ជកម្ម។[៥៤] បន្ទាប់ពីបានទទួលនូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ គេអាចធ្វើអាជីវកម្មដោយមាននូវគេហទំព័រ ឬកម្មវិធីដែលអាចឱ្យអ្នកដែលមានបំណងចង់ទិញទំនិញ ឬសេវាចូលទៅជ្រើសរើសបាន។ ម្យ៉ាងវិញទៀត បើទោះបីជាកិច្ចសន្យាពាណិជ្ជកម្មដែលបានបង្កើតឡើងតាមអន្តរកម្មនៃប្រព័ន្ធស្វ័យប្រវត្តិនេះ មិនមែនជាអន្តរកម្មធ្វើឡើងរវាងបុគ្គលនិងបុគ្គលជាក់ច្បាស់ដូចទៅនឹង កិច្ចសន្យាបង្កើតឡើងតាមប្រព័ន្ធអេឡិចត្រូនិករវាងភាគីក៏ដោយ ក៏មិនមានបុគ្គលណាមួយអាចបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យាក្រោមមូលហេតុនេះឡើយ។[៥៥] ការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រព័ន្ធស្វ័យប្រវត្តិមាន ៤ ដំណាក់កាលដូចជា ការជ្រើសរើសទំនិញ ការបញ្ជាទិញ ការទូទាត់ប្រាក់ និង ការដឹកជញ្ជូននិងទទួលទំនិញ។

[៥៤] ដដែល, ប្រការ៧។

[៥៥] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា១៧។

#### ២.១.២.១ ការជ្រើសរើសទំនិញ

អ្នកទិញ អាចចូលទៅកាន់គេហទំព័រ ឬ កម្មវិធីរបស់បុគ្គលដែលជាអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា រួចធ្វើការពិនិត្យមើលទំនិញ ឬសេវាប្រភេទណាមួយដែលខ្លួនចង់ធ្វើការទិញ ឬប្រើប្រាស់។ បន្ទាប់ពីបានឃើញនឹងសម្រេចចិត្តយកនូវប្រភេទទំនិញ ឬសេវានោះហើយ អ្នកទិញអាចធ្វើការជ្រើសរើសនូវ ទំហំ ពណ៌ ប្រភេទ មុខងារ ការបញ្ចុះតម្លៃ ឬព័ត៌មានផ្សេងៗទៀតដែលអ្នកទិញអាចធ្វើការជ្រើសរើសលើទំនិញ ឬសេវានោះ មុននឹងធ្វើការបញ្ជាទិញ។

#### ២.១.២.២ ការបញ្ជាទិញ

បន្ទាប់ពីបានជ្រើសរើសនូវព័ត៌មានរបស់ទំនិញនោះហើយ អ្នកទិញអាចទាញយកទំនិញនោះដាក់ក្នុងកន្ត្រក ដែលជាភាសាអង់គ្លេសហៅថា Shopping Cart រួចអាចធ្វើការពិនិត្យមើល ឬស្វែងរកនូវទំនិញផ្សេងៗទៀត។ នៅពេលដែលសម្រេចចិត្តធ្វើការបញ្ជាទិញ អ្នកទិញអាចចុចលើពាក្យបញ្ជាទិញ រួចត្រូវបំពេញនូវព័ត៌មានមួយចំនួនអំពីគណនីរបស់ខ្លួន។ ព័ត៌មានទាំងនោះមានដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ អ៊ីម៉ែល លេខសម្ងាត់។ល។ ប្រសិនបើមានគូប៉ុងសម្រាប់បញ្ចុះតម្លៃ អ្នកទិញអាចធ្វើការវាយបញ្ចូលលេខសម្ងាត់ ដើម្បីទទួលបានការបញ្ចុះតម្លៃផងដែរ។ ក្រោយពីបញ្ចូលព័ត៌មានរួចរាល់ អ្នកទិញអាចត្រួតពិនិត្យមើលជាថ្មី រួចអាចធ្វើការដាក់បញ្ជាទិញបាន ដោយបន្ទាប់គឺជាដំណាក់កាលទូទាត់ប្រាក់។

#### ២.១.២.៣ ការទូទាត់ប្រាក់

ការទូទាត់ប្រាក់ក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានវិធីនៃការទូទាត់ច្រើនបែប ដោយថ្លៃចំណាយពីការទិញទំនិញ ឬ សេវានោះអាចទូទាត់បានតាមរយៈប្រព័ន្ធអេឡិចត្រូនិកដែលមានដូចជាការទូទាត់តាមកាបូបអេឡិចត្រូនិក ដោយជាភាសាអង់គ្លេសហៅថា E-Wallets, កាតឥណទាន ឬឥណពន្ធ ដែលជាភាសាអង់គ្លេសហៅថា Credit Card or Debit Card និងការផ្ទេរប្រាក់តាមរយៈធនាគារនានា ឬបាគងជាដើម។ ចំណែកឯប្រភេទនៃការទូទាត់ប្រាក់មួយទៀតនោះគឺ ការទូទាត់តាមរយៈភ្នាក់ងារដឹកជញ្ជូនដោយផ្ទាល់ នៅពេលដែលភ្នាក់ងារដឹកជញ្ជូនបានប្រគល់ទំនិញមកដល់ដៃរបស់អតិថិជន។ ការទូទាត់ទាំងពីរបែបនេះបំពេញលក្ខខណ្ឌដូចគ្នា ដោយគ្រាន់តែការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកមានភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាពជាងការទូទាត់ប្រាក់ដោយប្រគល់ទៅកាន់អ្នកដឹកជញ្ជូន ព្រោះមានប្រតិបត្តិការទូទាត់ជាក់ច្បាស់នៅពេលដែលបានទូទាត់។

ជាក់ស្តែងនាពេលបច្ចុប្បន្ន ការទូទាត់ប្រាក់តាមរយៈប្រព័ន្ធអេឡិចត្រូនិកមានភាពពេញនិយម និង ឧស្សាហ៍ប្រើប្រាស់។ ជាទូទៅការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកនេះ មាន ៣ ដំណាក់កាល ដូចជា ដំណាក់កាលទី១ នៅពេលដែលបានជ្រើសរើសទំនិញ និងបានពិនិត្យលើទំហំ ពណ៌ ឬចំនួននៃទំនិញរួចរាល់ហើយនោះ អ្នកទិញអាចធ្វើការចុចលើពាក្យទូទាត់ រួចបំពេញនូវព័ត៌មានមួយចំនួនអំពីបែបបទទូទាត់ ករណីប្រសិនបើមិនទាន់មានការបំពេញ។ បែបបទព័ត៌មានដែលត្រូវបំពេញមានដូចជា លេខកាតធនាគារ កាលបរិច្ឆេទផុតកំណត់ លេខកូដCVV លេខកុងធនាគារ និងអាសយដ្ឋានរបស់ម្ចាស់កាតជាដើម។ នៅពេលដែលបំពេញរួចរាល់កាតធនាគារនឹងបានភ្ជាប់ជាមួយនឹងគេហទំព័រ ឬ កម្មវិធីរបស់ផលិតផលដែលចង់បញ្ជាទិញ។ ដំណាក់កាលទី ២ គឺធ្វើការពិនិត្យមើលនូវចំនួនទឹកប្រាក់ដែលត្រូវបង់ ផ្ទៀងផ្ទាត់ព័ត៌មានផ្សេងៗឱ្យបានគ្រប់ជ្រុងជ្រោយមុននឹងសម្រេចធ្វើការផ្ទេរប្រាក់។ ដំណាក់កាលទី ៣ គឺអ្នកទិញអាចចុចលើការទូទាត់ និងបញ្ជាក់ពីការទូទាត់របស់ខ្លួន ដោយជាទូទៅនឹងមានចេញនូវវិក្កយបត្រ ឬប្រតិបត្តិការដែលបានទូទាត់ហើយទាំងនៅក្នុងគេហទំព័រ និងក្នុងគណនីធនាគារដែលបានភ្ជាប់នោះ។[៥៦]

ប្រសិនបើចង់ធ្វើការទូទាត់តាមកាបូបអេឡិចត្រូនិកវិញ ក៏មិនមានភាពខុសគ្នាខ្លាំងពីការទូទាត់តាមធនាគារដែរ ដោយគ្រាន់តែគេហទំព័រ ឬកម្មវិធីខ្លះ មានកាបូបអេឡិចត្រូនិក ដែលជាភាសាអង់គ្លេសហៅថា E-Wallet ដែលតម្រូវឱ្យអ្នកទិញធ្វើប្រតិបត្តិការទូទាត់ ពីគណនីធនាគារមកកាន់កាបូបអេឡិចត្រូនិករបស់គេហទំព័រ ឬកម្មវិធីជាមុនសិន រួចទើបធ្វើប្រតិបត្តិការទូទាត់បន្តទៀតដូចដំណាក់កាលខាងលើដែរ។ ប្រតិបត្តិការទូទាត់ប្រាក់ដោយមានកាបូបអេឡិចត្រូនិក ពេលខ្លះអាចមានការបញ្ចុះតម្លៃ ឬការសន្សំពិន្ទុដែលជាប្រយោជន៍សម្រាប់អ្នកទិញ។[៥៧]

ក្រៅពីមធ្យោបាយនៃការទូទាត់ដោយផ្ទាល់ទៅកាន់អ្នកដឹកជញ្ជូន ការទូទាត់ប្រាក់តាមរយៈធនាគារ ឬ កាតឥណទាន ឬ កាបូបអេឡិចត្រូនិក គឺជាការទូទាត់ប្រាក់ដោយ មានបុគ្គលផ្តល់សេវាទូទាត់ចូលរួម។ បុគ្គលផ្តល់សេវាទូទាត់ គឺជានីតិបុគ្គល ឬគ្រឹះស្ថានដែលបានចូលរួមក្នុងការសម្របសម្រួលការទូទាត់ប្រាក់តាមរយៈប្រព័ន្ធអនឡាញ ពីអ្នកទិញ ឬអតិថិជន ទៅកាន់អ្នកផ្គត់ផ្គង់ទំនិញ ឬសេវានោះ។ បុគ្គលដែលផ្តល់សេវាទូទាត់នេះ ត្រូវមានការអនុញ្ញាត ឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា

[៥៦] GoCardless, "The Basics of Online Payment Processing" [មូលដ្ឋាននៃនីតិវិធីនៃការទូទាត់ប្រាក់តាមរយៈប្រព័ន្ធអនឡាញ], GoCardless (មិថុនា ២០២៣) ។

[៥៧] ដដែល។

ជាមុន ទើបអាចផ្តល់សេវាទូទាត់នេះបាន[៥៨] ដូចជា វីង (Wing), ទ្រូម៉ាន់នី (True Money), ផាយផេ (Pi Pay), ធនាគារអេស៊ីលីដា (ACELEDA BANK), និងធនាគារ អេប៊ីអេ (ABA BANK)។ល។

បុគ្គលដែលបានផ្តល់សេវាទូទាត់ មានការទទួលខុសត្រូវលើការប្រព្រឹត្តរបស់ខ្លួនមានដូចជាៈ[៥៩]

ក. ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

ខ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

គ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា ៤៨ ខាងក្រោម។

ឃ. ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន។ ឬ

ង. ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

### ២.១.២.៤ ការដឹកជញ្ជូន និង ទទួលទំនិញ

ទាក់ទងនឹងការដឹកជញ្ជូន គេឃើញមាននូវសេវាដឹកជញ្ជូនរបស់ក្រុមហ៊ុនរបស់អ្នកលក់ដោយផ្ទាល់ ឬក្រុមហ៊ុនឯកជនផ្សេងៗដែលផ្តល់សេវាក្នុងការដឹកជញ្ជូន។ ការចំណាយក្នុងការដឹកជញ្ជូន គឺស្របទៅនឹងចម្ងាយនៃទីតាំងរបស់អ្នកទិញ ដែលតាមជិត ឬឆ្ងាយ នៅក្នុងទីក្រុងឬតាមខេត្តជាដើម។ អ្នកដឹកជញ្ជូនទំនិញ នឹងប្រគល់ទំនិញនោះដល់អ្នកទិញដោយផ្ទាល់។

[៥៨] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា៤៦។

[៥៩] ដដែល, មាត្រា៤៧។

រូបទី៧៖ ការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រព័ន្ធស្វ័យប្រវត្តិ[៦០]




រូបទី៨៖ ទំនាក់ទំនងនៃការបង្កើតកិច្ចសន្យាធ្វើឡើងដោយប្រព័ន្ធស្វ័យប្រវត្តិ[៦១]




[៦០] https://www.ecommerceceo.com/learn/ecommerce-website/ (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២៤)។

[៦១] https://www.slideshare.net/slideshow/ecom-slidespptx/២៥៨៦២៥២៧២ (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២៤)។

### ២.១.៣ ការបង្កើតកិច្ចសន្យាតាមរយៈអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ក្រៅពីភាគីសងខាងនៃកិច្ចសន្យា ក៏មាននូវបុគ្គលមួយចំនួនទៀតដែលជាអ្នកសម្របសម្រួល និងចូលក្នុងសកម្មភាពនៃការធ្វើពាណិជ្ជកម្មនោះដែរ។ បុគ្គលទាំងនោះមាន អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

#### ២.១.៣.១ និយមន័យ និង តួនាទីរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

អន្តរការី ដែលជាភាសាអង់គ្លេសហៅថា Intermediary សំដៅដល់បុគ្គលដែលផ្តល់សេវា ផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិក រួមបញ្ចូលនូវបុគ្គលដូចខាងក្រោម៖[៦២]

១. បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬ អ្នករក្សាទុក
២. បុគ្គលផ្តល់សេវាទូរគមនាគមន៍
៣. បុគ្គលផ្តល់សេវាបណ្តាញនានា
៤. បុគ្គលផ្តល់សេវាអ៊ីនធឺណិត
៥. បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក
៦. បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ
៧. បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ
៨. បុគ្គលផ្តល់សេវាទីផ្សារអនឡាញ និងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ីនធឺណិត។

នៅក្នុងដំណើរការនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អន្តរការី អាចជាភ្នាក់ងារដែលជួយសម្របសម្រួលផ្នែកបច្ចេកទេស ដោយជួយក្នុងការផ្ទេរទំនិញ និងទូទាត់ប្រាក់នៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ អន្តរការី អាចជាក្រុមហ៊ុនផ្តល់សេវាទីផ្សារអនឡាញ ក្រុមហ៊ុនធានាលើការទូទាត់ប្រាក់ ក្រុមហ៊ុនអាម៉ាហ្សូន (Amazon Maketplace) និងក្រុមហ៊ុន FedEx ជាដើម។ បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាភាសាអង់គ្លេសហៅថា E-commerce Service Provider សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិក ដើម្បីផ្គត់ផ្គង់ទំនិញ និង/ឬ សេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។ ជាឧទាហរណ៍ Amazon.com, Alibaba.com, Shopify, Booking.com។ ល។

[៦២] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, ឧបសម្ព័ន្ធ។

ជារួម អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺជាបុគ្គលដែលចូលរួមនៅក្នុងដំណើរការនៃការធ្វើពាណិជ្ជកម្ម ដោយមានជាថ្នាលបច្ចេកវិទ្យា ឬកម្មវិធី ឬគេហទំព័រសម្រាប់ផ្តល់សេវាពាណិជ្ជកម្មជូនភាគីម្ខាងជាអ្នកប្រើប្រាស់សេវា ភ្ជាប់ជាមួយនឹងភាគីម្ខាងទៀតដែលជាអតិថិជន។ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនជាអ្នកផ្គត់ផ្គង់ទំនិញឬសេវា ឬអ្នកលក់ដោយផ្ទាល់នោះទេ គឺគ្រាន់តែជាអ្នកជួយសម្របសម្រួលប៉ុណ្ណោះ។

### ២.១.៣.២ ភាតព្វកិច្ចនៃការស្នើសុំអាជ្ញាបណ្ណ

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងនាមជាអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចស្នើសុំអាជ្ញាបណ្ណ ដោយក្រសួងពាណិជ្ជកម្មជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងផ្តល់ជូន។[៦៣] ការស្នើសុំអាជ្ញាបណ្ណនេះ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជានីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេស ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា៖[៦៤]

ក. បានចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ខ. មានវិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនកម្មសិទ្ធិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

គ. ប្រើមធ្យោបាយឬកម្មវិធីអេឡិចត្រូនិក សម្រាប់ធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ឃ. ប្រព័ន្ធអេឡិចត្រូនិកដែលនឹងត្រូវបានប្រើប្រាស់ ត្រូវមានសុក្រឹត្យភាពដូចមានកំណត់ក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ង. មានការបញ្ជាក់អំពីមធ្យោបាយទូទាត់។

ច. មានគំរូអាជីវកម្មនិងទម្រង់នៃកិច្ចការពារអ្នកប្រើប្រាស់។

ឆ. ក្នុងករណីនីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេសដែលជាអន្តរការី ត្រូវធ្វើកិច្ចសន្យាជាមួយបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវឱ្យផ្តល់ព័ត៌មានអប្បបរមា។

បន្ទាប់ពីបានបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ ក្រសួងពាណិជ្ជកម្មនឹងពិចារណាផ្តល់អាជ្ញាបណ្ណជូនដល់នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស។ អាជ្ញាបណ្ណនេះ មានសុពលភាពរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មផ្តល់អាជ្ញាបណ្ណជូន។[៦៥] បន្ថែមពីនេះ ក្រោយពីទទួលបាន

[៦៣] អនុក្រឹត្យស្តីពី ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង, លេខ ១៣៤ អនក្រ.បក, ០៧ សីហា ២០២០, មាត្រា៤។

[៦៤] ដដែល, មាត្រា៧។

[៦៥] ដដែល, មាត្រា៧។

អាជ្ញាបណ្ណសម្រាប់ផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចស្នើសុំវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានតាមការស្ម័គ្រចិត្ត។[៦៦] មិនតែប៉ុណ្ណោះ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មក៏អាចស្នើសុំនូវវិញ្ញាបនបត្រសេវាអនទ្បាញ ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានផងដែរ។[៦៧]

### ២.១.៣.៣ ភាតព្វកិច្ចនៃការទទួលខុសត្រូវ និង មិនទទួលខុសត្រូវ

អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាបុគ្គលដែលចូលរួមនៅក្នុងទំនាក់ទំនងនៃការបង្កើត ឬការធ្វើប្រតិបត្តិការនៃសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះដែរ។ បន្ថែមពីនេះ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏ទទួលបានចំណេញតាមរយៈការបម្រើសេវាកម្មរបស់ពួកគេ។ ដូច្នេះ ក្នុងនាមជា អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏មាននូវការទទួលខុសត្រូវ និង ការមិនទទួលខុសត្រូវទៅលើសកម្មភាពរបស់ខ្លួនដែលបានធ្វើ ឬមិនបានធ្វើ។ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅក្នុងកំណត់ត្រាអេឡិចត្រូនិក ក្នុងករណីដែលខ្លួនមិនបានដឹងថាព័ត៌មាននោះខុសច្បាប់ ឬមិនបានដឹងអំពីអង្គហេតុឬកាលៈទេសៈ ដែលបង្កឱ្យមានការទទួលខុសត្រូវនោះឡើយ។[៦៨] ពីព្រោះអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានតួនាទីគ្រាន់តែជាអ្នកផ្តល់សេវាផ្ញើ ទទួល ឬបញ្ជូនទិន្នន័យទៅកាន់អ្នកប្រើប្រាស់ជំនួស បុគ្គលផ្គត់ផ្គង់ទំនិញឬសេវាប៉ុណ្ណោះ ដោយមិនមែនជាអ្នកដែលមានឆន្ទៈដោយផ្ទាល់ ឬជាអ្នកផ្គត់ផ្គង់ដោយផ្ទាល់ក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។ ដូចនេះ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យមានការទទួលខុសត្រូវក្នុងផ្នែកនេះទេ។

បន្ថែមពីនេះ បុគ្គលដែលជាអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឱ្យតាមដាន និងត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួននោះឡើយ ទោះបីជាដំណើរការនៃកំណត់ត្រានោះអាចបង្កើតបានជាបទល្មើស ឬនាំឱ្យមានការទទួលខុសត្រូវក៏ដោយ។[៦៩] ប៉ុន្តែ បញ្ញត្តិដែលចែងពីការមិនទទួលខុសត្រូវមិនមានន័យថា អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចរួច

[៦៦] ដដែល, មាត្រា៨។

[៦៧] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា២៦។

[៦៨] ដដែល, មាត្រា២៤។

[៦៩] ដដែល, មាត្រា២៤។

ផុតពីការទទួលខុសត្រូវទាំងស្រុងនោះទេដោយការទទួលខុសត្រូវអាចកើតមានឡើងដោយកាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬ សេចក្តីបង្គាប់របស់តុលាការឬអាជ្ញាធរមានសមត្ថកិច្ច ឬតាមរយៈកិច្ចសន្យាជាដើម។[៧០]

ចំពោះផ្នែកព័ត៌មានវិញ អន្តរការី និងបុគ្គលសេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវមានករណីយកិច្ចនៅពេលដែលបានដឹងថាព័ត៌មាន ក្នុងកំណត់ត្រាអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ដោយត្រូវចាត់វិធានការជាបន្ទាន់ក្នុងការដកព័ត៌មាននោះចេញពីប្រព័ន្ធរួចរក្សាទុកជាភស្តុតាង និងជូនដំណឹងអំពីអង្គហេតុ និងអត្តសញ្ញាណនៃជនសង្ស័យ ទៅកាន់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និង ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។[៧១] ក្រោយពីទទួលបានការជូនដំណឹង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធផ្សេងៗទៀត នឹងធ្វើការបញ្ជាឱ្យដកព័ត៌មានចេញពីប្រព័ន្ធ ផ្អាក ឬឈប់ផ្តល់សេវាដល់បុគ្គលល្មើស ឬកំណត់ត្រាអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងបុគ្គលនោះទៀត។[៧២]

ការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈ អន្តរការី និងបុគ្គលផ្តល់សេវាតម្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលបានកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។[៧៣] ជាការឆ្លើយតបនឹងមាត្រានេះ ក៏មានការពិគ្រោះយោបល់ក្នុងការរៀបចំប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ដែលមានគោលបំណងដើម្បីគ្រប់គ្រងលើសកម្មភាព និងប្រតិបត្តិការក្នុងគោលដៅធានាការពារផលប្រយោជន៍ និងសិទ្ធិរបស់អ្នកប្រើប្រាស់ ក៏ដូចជាលើកកម្ពស់ទំនុកចិត្តក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។[៧៤]

---

[៧០] ដដែល។

[៧១] ដដែល, មាត្រា២៥។

[៧២] ដដែល។

[៧៣] ដដែល, មាត្រា២៧។

[៧៤] ក្រសួងពាណិជ្ជកម្ម, សិក្ខាសាលាពិគ្រោះយោបល់លើប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ២៣ ឧសភា ២០២៣។

## ២.២ ភាតព្វកិច្ចពន្ធចំពោះការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

ប្រភពចម្បងមួយនៃចំណូលរបស់រដ្ឋគឺ ការប្រមូលពន្ធ។ រាជរដ្ឋាភិបាល ជាពិសេសអគ្គនាយកដ្ឋានពន្ធដារ តែងដាក់ចេញនូវការធ្វើវិចារណកម្ម និងសម្រេចនូវការប្រមូលពន្ធមួយដែលសមប្រកបជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជាតិ កម្រិតនៃការវិនិយោគ និងសេដ្ឋកិច្ចរបស់ជាតិ។ រាជរដ្ឋាភិបាលបានកំណត់នូវសកម្មភាពនានាដែលត្រូវជាប់កាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ ហើយអគ្គនាយកដ្ឋានពន្ធដារគឺជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រង និងប្រមូលពន្ធអាករគ្រប់ប្រភេទផ្អែកតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។[៧៥] ទាក់ទងនឹងការធ្វើពាណិជ្ជកម្ម ពន្ធដែលសំខាន់ និងមានកាតព្វកិច្ចត្រូវបង់គឺប្រភេទពន្ធ អាករលើតម្លៃបន្ថែម ដែលត្រូវអនុវត្តលើរាល់ការផ្គត់ផ្គង់ជាប់អាករនូវទំនិញ ឬ សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៧៦] បុគ្គលដែលជាប់អាករលើតម្លៃបន្ថែមមានដូចជា បុគ្គលនិវាសនជនដែលបានជាប់ពន្ធតាមរបបស្វ័យប្រកាស និងបុគ្គលអនិវាសនជនដែលផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជា។[៧៧]

អាករលើតម្លៃបន្ថែម ត្រូវបានកំណត់តាមអាត្រា ១០% លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាតាមប្រព័ន្ធអេឡិចត្រូនិកមានអាត្រា ១០% ដូចគ្នាផងដែរ។ ដោយឡែក ចំពោះការផ្គត់ផ្គង់ទំនិញដែលនាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬ ការផ្គត់ផ្គង់សេវាជាប់អាករដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជាបានកំណត់តាមអាត្រា ០% លើតម្លៃជាប់អាការនៃការផ្គត់ផ្គង់។[៧៨]

### ២.២.១ ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធនិវាសនជន

អ្នកជាប់ពន្ធនិវាសជន សំដៅដល់រូបវន្តបុគ្គលទាំងឡាយដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ អ្នកជាប់ពន្ធនិវាសនជន សំដៅដល់នីតិបុគ្គល ឬ ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រង

[៧៥] អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លេខ៤៣ អនក្រ.បក, ២៨ កុម្ភៈ ២០២២, មាត្រា២០។
[៧៦] ច្បាប់ស្ដីពីសារពើពន្ធ, លេខ នស/រកម/០៥២៣/០០៤, ១៦ ឧសភា ២០២៣, មាត្រា៥៥-៥៦។
[៧៧] ដដែល, មាត្រា៥៨។
[៧៨] ដដែល, មាត្រា៦៥។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៧៩]

ក្នុងទំនាក់ទំនងអេឡិចត្រូនិក អ្នកជាប់ពន្ធនិវាសនជន គឺជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានចុះបញ្ជីតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៨០] នៅពេលផ្គត់ផ្គង់ទំនិញ ឬសេវា បុគ្គលដែលជាអ្នកផ្គត់ផ្គង់តែងមានចេញនូវវិក្កយបត្រ ដោយមានភ្ជាប់ ឬបូកអាករលើតម្លៃបន្ថែម ១០% លើទំនិញ ឬ សេវាដែលបានផ្គត់ផ្គង់នោះ។ ដូច្នេះ អ្នកប្រើប្រាស់ត្រូវបង់នូវអាករលើតម្លៃបន្ថែមទៅកាន់បុគ្គលផ្គត់ផ្គង់ទំនិញឬសេវារបស់ខ្លួន រួចបុគ្គលផ្គត់ផ្គត់ទំនិញ ឬសេវាត្រូវធ្វើការប្រមូល ប្រកាសពន្ធ និង បង់ប្រាក់អាករជារៀងរាល់ខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។[៨១] ចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាតាមប្រព័ន្ធអេឡិចត្រូនិក ពីនិវាសនជនទៅកាន់អាជីវកម្មដែលជាបុគ្គលជាប់អាករដូចគ្នានោះមានការបង់អាករដូចនឹងការផ្គត់ផ្គង់ទៅកាន់អ្នកប្រើប្រាស់ដែរ ដោយគ្រាន់តែប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញឬសេវាសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម ដែលត្រូវបានផ្គត់ផ្គង់ពីបុគ្គលជាប់អាករម្នាក់ទៀត មានការកាត់កងដោយអាករលើធាតុចូលដែលជាអាករទិញចូលនូវទំនិញឬសេវា ត្រូវកាត់កងចេញពី អាករលើធាតុចេញដែលជាអាករដែលបានលក់ចេញនូវទំនិញ ឬសេវានោះ។[៨២]

### ២.២.២ ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធអនិវាសនជន

អ្នកជាប់ពន្ធអនិវាសនជន សំដៅដល់បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន ដោយធ្វើការផ្គត់ផ្គង់ទំនិញឌីជីថល ឬ សេវាឌីជីថល តាមប្រព័ន្ធអេឡិចត្រូនិកពីក្រៅព្រះរាជាណាចក្រកម្ពុជា មកក្នុងព្រះរាជាណាចក្រកម្ពុជា។[៨៣] ក្នុងន័យនេះ ទោះបីជាអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាបានប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិកក្នុងការធ្វើពាណិជ្ជកម្មដោយមិនស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយក៏មានកាតព្វកិច្ចក្នុងការបង់ពន្ធផងដែរ។ ដោយយោងតាមអនុក្រឹត្យស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម

[៧៩] ដដែល, មាត្រា៥។

[៨០] អនុក្រឹត្យស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ៦៥ អនក្រ.បក, ០៨ មេសា ២០២១, មាត្រា៣។

[៨១] ច្បាប់ស្តីពីសារពើពន្ធ, លេខ នស/រកម/០៥២៣/០០៤, ១៦ ឧសភា ២០២៣, មាត្រា៧១។

[៨២] ដដែល, មាត្រា៦៨។

[៨៣] អនុក្រឹត្យស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ៦៥ អនក្រ.បក, ០៨ មេសា ២០២១, មាត្រា៣។

ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិកដែលធ្វើឡើងដោយអនិវាសនជន។ អ្នកជាប់ពន្ធអនិវាសនជន មានកាតព្វកិច្ចត្រូវចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិចត្រូនិក ដែលភាសាអង់គ្លេសហៅថា E-Registration ដោយត្រូវបំពេញទម្រង់ចុះបញ្ជីដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។[៩៤] ការចុះបញ្ជី គឺផ្អែកតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលមានដូចជា អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ។ ក្រោយពីបានចុះបញ្ជីពន្ធដារ អ្នកជាប់ពន្ធអនិវាសនជនត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ ដោយរយៈពេលនៃការបង់ពន្ធយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលបានទូទាត់។[៩៥]

ចំពោះអនិវាសនជន ដែលបានផ្គត់ផ្គង់ទំនិញ ឬសេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានពីរទម្រង់។ ដូចជា ទីមួយ គឺការផ្គត់ផ្គង់ទំនិញ ឬសេវាពីអាជីវករទៅអ្នកប្រើប្រាស់ ដែលជាការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬរាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីបុគ្គលជាប់អាករដែលជាអនិវាសនជន ទៅកាន់អ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ដាក់លិខិតប្រកាស និង បង់អាករលើតម្លៃបន្ថែមមករដ្ឋបាលសារពើពន្ធ។[៩៦] ទីពីរ គឺការផ្គត់ផ្គង់ទំនិញ ឬសេវា ពីអាជីវករទៅអាជីវករ ដែលជាផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ឬ រាល់សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីបុគ្គលអនិវាសនជន ឬបុគ្គលជាប់អាករ ទៅបុគ្គលជាប់អាករដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវប្រមូលអាករតាម វិធីគិតអាករជំនួសដែលជាភាសាអង់គ្លេសហៅថា Reverse Charge ហើយធ្វើការប្រកាស និងបង់អាករមករដ្ឋបាលសារពើពន្ធ។[៩៧]

### ២.២.៣ មធ្យោបាយនៃការទូទាត់ប្រាក់ពន្ធ

ការបង់ប្រាក់ចំពោះអាករលើតម្លៃបន្ថែម ទៅកាន់អគ្គនាយកពន្ធដារអាចធ្វើឡើងតាមមធ្យោបាយដូចជា ទីមួយ គឺការទូទាត់បង់ប្រាក់អាករលើតម្លៃបន្ថែមនៅធនាគារក្នុងស្រុក ដែលជាដៃគូររបស់អគ្គនាយកដ្ឋានពន្ធដារដែលមានដូចជា ធនាគារអេស៊ីលីដា ភីអិលស៊ី ឬ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ឬ ធនាគារវឌ្ឍនៈ ឬ ធនាគារកម្ពុជាសាធារណៈភីអិលស៊ី ឬ ធនាគារស្ថាបនាភីអិលស៊ី ឬ ធនាគារ

[៩៤] ដដែល, មាត្រា៤។

[៩៥] ដដែល, មាត្រា៥។

[៩៦] ដដែល, មាត្រា៣៦។

[៩៧] ដដែល។

កាណាឌីយ៉ាង ក.អ ឬ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ ឬ ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ ឬ ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។ ការទូទាត់តាមធនាគារ អាចជាការទូទាត់ជាសាច់ប្រាក់ដោយផ្ទាល់ ឬ តាម រយៈអនឡាញ ដែលជាភាសាអង់គ្លេសហៅថា E-Payment ដែលជាភាពងាយស្រួលដល់អនិវាសជនដូចគ្នាក្នុងការទូទាត់។ បន្ថែមពីនេះ ចំពោះអនិវាសនជនអាចធ្វើការផ្ទេរប្រាក់ពីបរទេស មកគណនីរបស់ អគ្គនាយកដ្ឋានពន្ធដារតាមរយៈធនាគារក្នុងស្រុកដែលជាដៃគូរដូចបានរៀបរាប់ខាងលើ។ ការទូទាត់តាមមធ្យោបាយធនាគារនេះ គឺអនិវាសនជនអាចប្រើប្រាស់អ្នកតំណាង ឬ ភ្នាក់ងារសេវាកម្មពន្ធដារណាមួយ ដើម្បីរៀបចំទូទាត់បង់ប្រាក់ជំនួសជូនអគ្គនាយកដ្ឋានពន្ធដារបាន។ ទីពីរ គឺការទូទាត់អាករលើតម្លៃបន្ថែមដោយប្រើប្រាស់កាតឥណទាន ឬកាតឥណពន្ធ ដែលជាភាសាអង់គ្លេសហៅថា Credit Card or Debit Card។ ទីបី គឺការទូទាត់អាករលើតម្លៃបន្ថែមនៅអគ្គនាយកដ្ឋានពន្ធដារដោយផ្ទាល់។[៩៨]

## ២.៣ កិច្ចការពារអ្នកប្រើប្រាស់ចំពោះការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលជួយសម្របសម្រួល និងការពារជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកក្នុងការធ្វើពាណិជ្ជកម្ម។ ជាពិសេសគឺ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលកម្ពុជាបានប្រកាសឱ្យប្រើកន្លងមកដោយមិនត្រឹមតែជួយសម្រួលក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យកាន់តែមានភាពរលូននោះទេ វាក៏មាននូវបញ្ញត្តិដែលចែងទាក់ទងនឹងការការពារដល់អ្នកប្រើប្រាស់ផងដែរ ដែលជួយដល់អ្នកប្រើប្រាស់ពីការខាតបង់ផលប្រយោជន៍នានា និងការពារសុវត្ថិភាពរបស់អ្នកប្រើប្រាស់។ បន្ថែមពីនេះ បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។[៩៩]

ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ឆ្នាំ២០១៩ មានគោលដៅការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងធ្វើឱ្យភាគីមានទំនុកចិត្តចំពោះគ្នាទៅវិញទៅមក។ មិនត្រឹមតែប៉ុណ្ណោះ ដើម្បីការពារអ្នកប្រើប្រាស់បន្ថែមទៀត ក៏មានការបង្កើតឡើងនូវការប្រជុំ និងពិគ្រោះយោបល់លើការរៀបចំប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ ដែលរៀបចំឡើងដោយអន្តរក្រសួងនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួង

---

[៩៨] អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, *កម្រងសំណួរដែលសួរជាញឹកញាប់ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* (ភ្នំពេញ៖ ២០២២), ២៥, https://www.facebook.com/story.php/?story_fbid=៣២២៥១១២៨៣៣៧៩៦២៣&id=១០០០៦៨៦២២៦២០០៣៥ ។

[៩៩] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា៣៣។

ពាណិជ្ជកម្មនាពេលកន្លងមក។[៩០] ជារួមចំពោះកិច្ចការពារអ្នកប្រើប្រាស់មានដូចជា កិច្ចការពារនូវការអនុវត្តសកម្មភាពទុច្ចរិត កិច្ចការពារចំពោះការលក់ទំនិញដោយភ្ជាប់សេចក្តីបរិយាយមិនពិត និងកិច្ចការពារលើទិន្នន័យរបស់អ្នកប្រើប្រាស់។

### ២.៣.១ កិច្ចការពារចំពោះការរខនូវការអនុវត្តសកម្មភាពទុច្ចរិត

សកម្មភាពទុច្ចរិត តែងកើតមានឡើងពីការបោកប្រាស់ ភូតភរ បោកបញ្ឆោតរបស់អាជីវករ ឬអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា។ នៅពេលខ្លះអ្នកទិញបានទិញនូវទំនិញ ឬសេវា ព្រមទាំងបានទូទាត់ប្រាក់រួចរាល់ទៀតផង ប៉ុន្តែបែរជាអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាមិនព្រមធ្វើការផ្គត់ផ្គង់ឱ្យទៅវិញ។ គ្រប់បុគ្គលដែលធ្វើធុរកិច្ច មិនត្រូវបង្កើតឱ្យមាននូវលក្ខណៈនៃការបំភាន់ ឬ បោកបញ្ឆោតដល់សាធារណៈជនទាក់ទងនឹងប្រភេទ ដំណើរការផលិត ចរិតលក្ខណៈ ភាពសមតាមបំណង បរិមាណ រង្វាស់រង្វាល់ក្រិតខ្នាត ស្តង់ដា ឬ គុណភាពនៃទំនិញឡើយ។[៩១] ដូច្នេះ ច្បាប់បានចែងការពារថា ក្នុងករណីដែលអ្នកផ្គត់ផ្គង់ទំនិញ ឬសេវានោះមិនមានបំណងផ្គត់ផ្គង់ទេ ឬ ទំនិញឬសេវាដែលអ្នកទិញបានធ្វើការបញ្ជាទិញមិនដូចនឹងទំនិញ ឬសេវារបស់ខ្លួនទេ ឬ មិនអាចផ្គត់ផ្គង់ឱ្យទាន់ពេលវេលាឬក្នុងពេលកំណត់ទៅកាន់អ្នកទិញដោយមានមូលហេតុសមស្របនោះទេ អ្នកផ្គត់ផ្គង់មិនត្រូវទាមទារ ឬ ទទួលយកការទូទាត់ណាមួយពីអ្នកទិញឡើយ។[៩២] ប្រសិនបើមានចេតនាក្នុងការប្រព្រឹត្តអំពើដែលប្រាសចាកនឹងបញ្ញត្តិនេះ បុគ្គលដែលប្រព្រឹត្តនឹងត្រូវទទួលនូវការពិន័យអន្តរការណ៍មិនលើសពី ៥០ ០០០ ០០០រៀល។[៩៣] ច្បាប់ចែងបែបនេះ គឺដើម្បីការពារអ្នកដែលទទួលរងនូវអំពើទុច្ចរិត និង ការពារមិនឱ្យអ្នកប្រព្រឹត្តហ៊ានប្រព្រឹត្តនូវអំពើល្មើសទាំងនោះទៀត។ ជាឧទាហរណ៍ លោក ក បានធ្វើសំណើតាមរយៈគេហទំព័រលក់អីវ៉ាន់របស់លោក ខ។ លោក ក បានធ្វើសំណើក្នុងការទិញទំនិញនោះយ៉ាងច្បាស់លាស់ថា លោកត្រូវការអីវ៉ាន់ដែលមានគុណភាពល្អ និង ដឹកជញ្ជូនមកឱ្យទាន់ពេលវេលាដែលលោកកំណត់ ដើម្បីដាក់តាំងក្នុងពិធីឡើងគេហដ្ឋានរបស់លោក។ លោក ខ ជាអ្នកលក់បានផ្តល់នូវស្វីការមួយយ៉ាងច្បាស់ និងទទួលយល់ព្រមនូវអ្វីដែលបានដាក់ស្នើទាំងអស់ ប៉ុន្តែលោក ខ បានដឹងហើយថាអីវ៉ាន់នឹងមិនអាចមកដល់ទាន់ពេលវេលានោះទេ។ លុះដល់ពេលកំណត់ លោក ខ មិនមានអីវ៉ាន់ជូនលោក ក នោះទេ ដែលធ្វើឱ្យលោក ក មិនសប្បាយចិត្ត និងប្តឹងទៅកាន់លោក ក ពីការឆបោកនេះ។ ក្នុងករណីនេះ មិនត្រឹម

[៩០] ក្រសួងពាណិជ្ជកម្ម, *សិក្ខាសាលាពិគ្រោះយោបល់ លើប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*, ២៣ ឧសភា ២០២៣។

[៩១] ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់, លេខ នស/រកម/១១១៩/០១៦, ២ វិច្ឆិកា ២០១៩, មាត្រា១០។

[៩២] ដដែល, មាត្រា១៧។

[៩៣] ដដែល, មាត្រា៥៤។

តែលោក ខ ត្រូវសងសំណងផ្សេងៗទៅកាន់លោក ក នោះទេ លោក ខ ក៏ត្រូវទទួលរងនូវការពិន័យអន្តរការណ៍ដូចដែលច្បាប់បានកំណត់ផងដែរ។

### ២.៣.២ កិច្ចការពារចំពោះការលក់ទំនិញដោយភ្ជាប់សេចក្តីបរិយាយមិនពិត

ក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពាណិជ្ជករជាអ្នកធ្វើការបរិយាយ ឬ ផ្សព្វផ្សាយទំនិញ ឬ សេវារបស់ខ្លួន ទៅកាន់អ្នកប្រើប្រាស់តាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ការបរិយាយ ឬ ការផ្សព្វផ្សាយនោះ ពាណិជ្ជករជាអ្នកត្រូវផ្តល់នូវព័ត៌មានមួយដែលត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់ដើម្បីឱ្យអ្នកប្រើប្រាស់អាចទទួលបានព័ត៌មានមួយពិតប្រាកដ និងអាចធ្វើការសម្រេចចិត្តបាន។ ក្នុងនោះបុគ្គលដែលជាអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវលាតត្រដាងនូវព័ត៌មានជាអប្បបរមាដល់អ្នកប្រើប្រាស់ដូចខាងក្រោម៖[៩៤]

ក. ឈ្មោះ ឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនង ឬលេខទូរសព្ទ។

ខ. ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ. ខ ចែងលក្ខខណ្ឌ និងសោយហ៊ុយរបស់ទំនិញ ឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខ ចែងលក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដក ឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់មកវិញ។ និង

ឃ. ទំនិញ និងសេវាជាក់ស្តែងដែលជាក់លាក់។

ក្នុងករណីដែលបុគ្គលផ្គត់ផ្គង់ មិនបានអនុវត្តស្របតាមបញ្ញត្តិស្តីពី ការផ្តល់ព័ត៌មានអប្បបរមាក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ បុគ្គលនេះនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវអំពើដែលបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិដែលច្បាប់បានចែង និងត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ។[៩៥] បន្ថែមពីនេះ ប្រសិនបើទទួលបានការព្រមានម្តងរួចហើយ ប៉ុន្តែនៅតែបន្តប្រព្រឹត្តនូវអំពើដែលផ្ទុយនឹងបញ្ញត្តិនេះទៀត បុគ្គលនោះនឹងត្រូវដកហូត ឬព្យួរអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតជាបុគ្គលផ្តល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់ខ្លួន។[៩៦]

---

[៩៤] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា២៩។
[៩៥] ដដែល, មាត្រា៥៧។
[៩៦] ដដែល។

អ្នកផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវមាននូវព័ត៌មានទាំងអស់នេះជាអប្បបរមា និងភ្ជាប់ជាមួយនឹងការបរិយាយ ឬការអះអាងដោយពិតប្រាកដស្របតាមការពិតរបស់ទំនិញ ឬសេវារបស់ខ្លួន។ ព័ត៌មានដែលបានលាតត្រដាងនេះ គឺអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា មិនត្រូវភ្ជាប់នូវសេចក្តីបរិយាយពីពាណិជ្ជកម្មមិនពិតឡើយ ដោយការបរិយាយមិនពិតមានន័យថា ជាការបរិយាយដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទំនិញ ឬ ការជំរុញការផ្គត់ផ្គង់ទំនិញតាមគ្រប់មធ្យោបាយ ឬការប្រើប្រាស់ទំនិញដែលត្រូវបានចាត់ទុកថាមិនពិតជាដើម។[97] ម្យ៉ាងវិញទៀត ច្បាប់បានការពារអ្នកប្រើប្រាស់ដោយបញ្ញត្តិច្បាស់ថា"បុគ្គលណាមួយមិនត្រូវធ្វើការអះអាងទាក់ទងនឹងការទទួលចំណេញ ហានិភ័យ ឬសារៈសំខាន់ផ្សេងៗទៀតដែលមិនពិត ឬដែលបំភាន់ចំពោះទំនិញ ឬសេវារបស់ខ្លួននោះឡើយ។"[98]

ជាក់ស្តែងអ្នកប្រើប្រាស់តែងជួបនូវការបរិយាយមិនពិតរបស់អ្នកផ្គត់ផ្គង់ ដោយពេលខ្លះបុគ្គលដែលផ្គត់ផ្គង់បានផ្តល់នូវការផ្សព្វផ្សាយមួយដែលមើលទៅច្បាស់លាស់ សមស្រប និងមានតម្លៃសមរម្យ ប៉ុន្តែនៅពេលដែលផ្គត់ផ្គង់ បែរជាមិនដូចទៅនឹងការផ្សព្វផ្សាយ។ វាអាចជាការលក់នៅក្នុងតម្លៃផ្សេងដែលមិនដូចនឹងការផ្សព្វផ្សាយនោះទេ ដែលនេះជាការផ្សព្វផ្សាយ ឬជាការបរិយាយមិនពិតផងដែរ។ ច្បាប់បានហាមឃាត់នូវអំពើទាំងឡាយដែលបុគ្គលជាផ្គត់ផ្គង់ទំនិញ ឬសេវាដោយមិនត្រូវផ្សព្វផ្សាយក្នុងថ្លៃជាក់លាក់ណាមួយ ហើយបានធ្វើឱ្យអ្នកប្រើប្រាស់ជឿជាក់ ប៉ុន្តែបែរជាបុគ្គលដែលផ្គត់ផ្គង់នោះមិនបានផ្តល់នូវតាមថ្លៃដែលបានផ្សាយ។[99] ជាឧទាហរណ៍ លោក ក ជាអ្នកលក់ផលិតផល ដោយដាក់លក់ផលិតផលមួយដែលបានផ្សព្វផ្សាយក្នុងតម្លៃ ២០ដុល្លារអាមេរិក។ លោក ខ ជាអ្នកប្រើប្រាស់បានដាក់ទិញនូវផលិតផលនោះតាមរយៈគេហទំព័រ។ ប៉ុន្តែនៅពេលដែលធ្វើការទំនាក់ទំនងជាមួយនឹងលោក ក ពេលនោះ លោក ក បានប្រាប់វិញថាតម្លៃផលិតផលគឺ ៣០ដុល្លារអាមេរិក។ ដូចនេះ ការផ្តល់តម្លៃក្នុងការលក់ និងតម្លៃដែលបានដាក់ផ្សព្វផ្សាយមិនដូចគ្នានោះទេ ដែលជាការបរិយាយមិនពិតរបស់លោក ក ដែលជាអ្នកលក់នូវតម្លៃផលិតផលរបស់ខ្លួន ដើម្បីឱ្យអ្នកទិញជឿនូវការបរិយាយ។ នៅពេលដែលមានការអះអាង ឬ ការបរិយាយមិនពិតបែបនេះ លោក ក នឹងត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ហើយប្រសិនបើនៅតែបន្តប្រព្រឹត្តល្មើសទៀត លោក ក អាចត្រូវព្យួរ ដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬអាជ្ញាបណ្ណ និងត្រូវទទួលរងការពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ២០ ០០០ ០០០ រៀលថែមទៀតផង។[100]

[97] ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់, លេខ នស/រកម/១១១៩/០១៦, ២ វិច្ឆិកា ២០១៩, មាត្រា២១។
[98] ដដែល, មាត្រា១៨។
[99] ដដែល, មាត្រា១៥។
[100] ដដែល, មាត្រា៤១។

### ២.៣.៣ កិច្ចការពារលើទិន្នន័យរបស់អ្នកប្រើប្រាស់

ក្នុងពេលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្គត់ផ្គង់ទំនិញឬសេវា និងបុគ្គលប្រើប្រាស់ ឬ អាចហៅបានថា អ្នកលក់ និងអ្នកទិញប្រាដកជាមានព័ត៌មានសំខាន់ដែលបានដាក់បញ្ចូល ឬ រក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិកសម្រាប់ប្រើប្រាស់នាពេលក្រោយទៀត។ អ្នកប្រើប្រាស់តែងផ្តល់នូវទិន្នន័យរបស់ខ្លួនណាមួយ ទៅកាន់បុគ្គលផ្គត់ផ្គង់ទំនិញ ឬសេវាតាមរយៈប្រព័ន្ធអេឡិចត្រូនិកនេះ។ ជាក់ស្តែង ប្រទេសកម្ពុជា មិនទាន់មាននូវច្បាប់ស្តីពីការការពារទិន្នន័យបុគ្គលអ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិកណាមួយឱ្យបានប្រាដកប្រជានៅឡើយទេ។ នាពេលបច្ចុប្បន្ន ប្រទេសកម្ពុជាមានតែច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប៉ុណ្ណោះ ដែលមានមាត្រាចែងពីកិច្ចការពារទិន្នន័យរបស់អ្នកប្រើប្រាស់។ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏បានកំណត់និយមន័យពាក្យ "ទិន្នន័យ" ថាជាបណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីឌីអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក។[១០១] នៅពេលធ្វើពាណិជ្ជកម្ម អ្នកប្រើប្រាស់តែងតែត្រូវបញ្ចូលទិន្នន័យផ្ទាល់ខ្លួនក្នុងគេហទំព័រ ឬថ្នាលបច្ចេកវិទ្យា ឬផ្ញើទៅកាន់បុគ្គលដែលជាអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា ដោយទិន្នន័យផ្ទាល់ខ្លួនទាំងនោះអាចជា ឈ្មោះ អាសយដ្ឋាន លេខអត្តសញ្ញាណបណ្ណ អ៊ីមែល លេខកុងធនាគារ។ល។ ដូច្នេះហើយ ដើម្បីធានាថាអ្នកប្រើប្រាស់បានបញ្ចូលទិន្ន័យរបស់ខ្លួនដោយមានសុវត្ថិភាព និងមិនលេចចេញនូវព័ត៌មានទាំងអស់នោះនៅពេលណាមួយ បុគ្គលដែលជាអ្នកផ្គត់ផ្គង់ទំនិញឬសេវា គឺជាអ្នកដែលមានទំនួលខុសត្រូវ និងធានាយ៉ាងណាថាប្រព័ន្ធអេឡិចត្រូនិកដែលខ្លួនប្រើមានសុវត្ថិភាពចំពោះអ្នកប្រើប្រាស់។

ជាហេតុ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានកំណត់នូវកាតព្វកិច្ចរបស់បុគ្គលផ្គត់ផ្គង់ទំនិញ ឬសេវា ក្នុងការការពារទិន្នន័យឯកជនរបស់អ្នកប្រើប្រាស់ ដោយបុគ្គលដែលរក្សាព័ត៌មានឯកជន ត្រូវធានាថាព័ត៌មានត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈ សមហេតុផល និងប្រើប្រាស់នូវគ្រប់មធ្យោបាយទាំងអស់ក្នុងការពារ។ នេះគឺដើម្បីជៀសវាងនូវការបាត់បង់ ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំងនោះ។[១០២] ម្យ៉ាងវិញទៀត បុគ្គលទាំងឡាយអាចចូលប្រើប្រាស់ក្នុងប្រព័ន្ធអេឡិចត្រូនិក ដោយទាញយក ថតចម្លង ស្រង់យក ធ្វើឱ្យបែកធ្លាយ លុបបំបាត់ ឬកែប្រែទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀតបាន លុះត្រាតែ

---

[១០១] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, ឧបសម្ព័ន្ធ, ៩។
[១០២] ដដែល, មាត្រា៣២។

បុគ្គលនោះធ្វើឡើងដោយមិនមានការជ្រៀតចូលក្នុងប្រព័ន្ធអេឡិចត្រូនិកដោយទុច្ចរិត ឬចូលទៅប្រើប្រាស់បានដោយមានការអនុញ្ញាតពីម្ចាស់ទិន្នន័យផ្ទាល់ជាមុន។[១០៣]

ការរក្សាទុកនូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នេះ មិនមានកាលកំណត់នោះទេ ដោយច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនបានកំណត់ពីអប្បបរមាក្នុងការរក្សាទុកទិន្នន័យនោះឡើយ។ ដូច្នេះ ទិន្នន័យដែលបានបញ្ចូលទាំងឡាយត្រូវរក្សាទុកក្នុងរយៈពេលសមរម្យ។ ការរក្សាទុកទិន្នន័យឱ្យមានសុវត្ថិភាព និងការពារទិន្នន័យរបស់អ្នកប្រើប្រាស់បែបនេះព្រោះវាមានសារៈសំខាន់សម្រាប់អតិថិជនដែលជាអ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ក្នុងការបញ្ជាទិញទំនិញ ឬសេវាកម្ម ដោយហេតុថាពេលខ្លះទិន្នន័យដែលបានបញ្ចូលត្រូវបានជនខិលខូចលួចយកទៅប្រើប្រាស់ក្នុងបំណងមិនល្អ។ ក្នុងករណីបុគ្គលដែលមានកាតព្វកិច្ចរក្សាទុកទិន្នន័យ បានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិដែលបានចែងក្នុងកិច្ចការពារនេះ បុគ្គលនោះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០រៀលទៅ ៤ ០០០ ០០០រៀល។[១០៤]

ទោះបីជាមិនមានច្បាប់ណាមួយដែលបានចែងជាក់ច្បាស់ពី ការការពារទិន្នន័យក្រៅពីច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយ ក្នុងករណីបើបុគ្គលផ្គត់ផ្គង់ទំនិញ ឬសេវា បានធ្វើឱ្យលេចចេញនូវព័ត៌មានឯកជនរបស់អ្នកប្រើប្រាស់ នោះនឹងនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ្នកប្រើប្រាស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ព្រមទាំងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដូចគ្នា។ យោងតាមមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា ក្នុងការធានាមិនត្រូវមានការរំលោភលើលំនៅឋាន និង អាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទឡើយ។[១០៥] បន្ថែមពីនេះ វាអាចប៉ះពាល់ដល់សិទ្ធិបុគ្គលដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដោយសិទ្ធិបុគ្គល សំដៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយសុខភាព សេរីភាព នាម កត្តិយស ភាពឯកជន ឬសិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណៈបុគ្គល។[១០៦]

[១០៣] ដដែល។

[១០៤] ដដែល, មាត្រា៦០។

[១០៥] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, មាត្រា៤០។

[១០៦] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១២០៧/០៣០/, ០៨ ធ្នូ ២០០៧, មាត្រា១៣។

# ជំពូកទី ៣
# បញ្ហាប្រឈម និង ដំណោះស្រាយចំពោះការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយចំពោះការធ្វើពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រូនិក

## ៣.១ បញ្ហាប្រឈម

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានបញ្ហាប្រឈមកើតឡើងច្រើន ដូចបញ្ហាផ្សេងៗនៃការធ្វើពាណិជ្ជកម្មតាមទម្រង់ទូទៅដែរ។ ទោះបីជាការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ធ្វើឡើងតាមរយៈការព្រមព្រៀងរវាងភាគីនិងភាគី ឬ ការយល់ព្រមគ្នា និងស្រុះស្រួលគ្នាទៅវិញទៅមកក៏ដោយ បញ្ហាប្រឈមនានានៅតែអាចកើតមាន។ បញ្ហាប្រឈមទាំងនោះ អាចកើតឡើងដោយភាគីនៃកិច្ចសន្យាបាត់បង់ជំនឿទុកចិត្តរវាងគ្នា បញ្ហានៃការទូទាត់ប្រាក់ ឬ ការមិនអនុវត្តកាតព្វកិច្ចផ្សេងៗ (៣.១.១)។ បន្ថែមពីនេះ បញ្ហាប្រឈមខ្លះទៀតមិនមែនកើតមានឡើងតែពីភាគីនៃការធ្វើពាណិជ្ជកម្មនោះទេ ពេលខ្លះអាចជាបញ្ហាទាក់ទិននឹងកង្វះខាតផ្នែកច្បាប់ និងផ្នែកបច្ចេកវិទ្យា (៣.១.២) ដូចជាប្រព័ន្ធអេឡិចត្រូនិកដំណើរការមិនទាន់បានល្អ ឬមិនមានភាពរលូនជាដើម និងបញ្ហាប្រឈមទាក់ទងនឹងតតិយជន ដែលជាជនខិលខូចបានបង្កើតជាបទល្មើសដោយបំពានទៅលើសិទ្ធិរបស់អ្នកប្រើប្រាស់ (៣.១.៣)។

### ៣.១.១ បញ្ហាទំនុកចិត្តរបស់ភាគីនៃការធ្វើពាណិជ្ជកម្ម

ការធ្វើពាណិជ្ជកម្មមួយ ទំនុកចិត្តរបស់ភាគីទាំងសងខាងគឺសំខាន់ណាស់។ នៅពេលដែលបាត់បង់នូវទំនុកចិត្ត នោះការប្រព្រឹត្តទៅនៃពាណិជ្ជកម្មក៏មិនមានភាពរលូនដែរ។ ក្នុងពេលដែលចាប់ផ្តើមធ្វើពាណិជ្ជកម្ម ភាគីមានឆន្ទៈពិតប្រាកដក្នុងការបង្កើតកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក ប៉ុន្តែបន្ទាប់ពីពេលកន្លងទៅ ភាគីនៃកិច្ចសន្យាអាចនឹងមានការផ្លាស់ប្តូរ ដោយមិនអនុវត្តកាតព្វកិច្ច មិនធ្វើការទូទាត់ប្រាក់ ឬមិនប្រព្រឹត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាជាដើម ដែលធ្វើឱ្យទំនុកចិត្តមានការធ្លាក់ចុះ និងប៉ះពាល់ដល់ទំនាក់ទំនងក្នុងពាណិជ្ជកម្មទាំងមូល។ ទំនុកចិត្ត ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនការទុកចិត្តរវាងអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា និង អ្នកទទួល។ បញ្ហាដែលនាំឱ្យបាត់បង់ទំនុកចិត្តរវាងគ្នានេះ កើតឡើងដោយសារមូលហេតុមួយចំនួនដូចជា ការមិនទុកចិត្តលើគុណភាពផលិតផល និងការមិនទុកចិត្តលើភាគីក្នុងការអនុវត្តកាតព្វកិច្ច។

បញ្ហាទំនុកចិត្តទាក់ទងនឹងគុណភាពផលិតផលគឺ អ្នកទិញ ឬអ្នកទទួលការផ្គត់ផ្គង់ទំនិញ ឬសេវា មានការព្រួយបារម្ភលើគុណភាពនៃទំនិញ ឬសេវាដែលខ្លួនចង់ទិញ ឬប្រើប្រាស់។ ដោយសារមូលហេតុ ក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនបានឃើញដោយផ្ទាល់នូវទំនិញ ឬសេវានោះទេ ដែលអាចជាការប្រឈមនឹងបញ្ហាមួយដែលអ្នកទិញអាចនឹងជួបប្រទះ។ ម្យ៉ាងវិញទៀតពេលខ្លះ

អ្នកទិញមិនបានទទួលនូវទំនិញ ឬ សេវាដូចការផ្សព្វផ្សាយ ឬ ការបរិយាយរបស់អ្នកផ្គត់ផ្គង់ទំនិញ ឬ សេវានោះទេ ដោយជាញឹកញាប់ការដាក់ចេញនូវទំនិញ ឬ សេវា មានគុណភាពមិនដូចអ្វីដែលបានសន្យា ដែលធ្វើឱ្យអ្នកទទួលមានការខកចិត្តនិងមិនពេញចិត្តក្នុងការធ្វើពាណិជ្ជកម្ម។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានភាពលំបាកក្នុងការកំណត់ថា គុណភាពនៃទំនិញនោះដូចនឹងអ្វីដែលអ្នកទិញចង់បាន ពីព្រោះអ្នកទិញមិនបានឃើញដោយផ្ទាល់នៅពេលដែលបង្កើតកិច្ចសន្យាពាណិជ្ជកម្មនោះទេ។ ទោះជាយ៉ាងនេះក្តី ក្នុងនាមជាអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវរក្សានូវភាពទៀងត្រង់ និង សុចរិតរបស់ខ្លួន ដោយបរិយាយនូវគុណភាពពិតប្រាកដរបស់ទំនិញ ឬ សេវានោះ។ ប្រសិនបើទំនុកចិត្តរបស់អ្នកទិញ នៅតែបន្តប្រឈមនឹងការជួបប្រទះបែបនេះ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកអាចនឹងមានការថយចុះបន្តិចម្តងៗ។

បញ្ហាចម្បងមួយទៀតនោះ គឺការមិនទុកចិត្តលើភាគីក្នុងការអនុវត្តកាតព្វកិច្ច។ នៅពេលដែលកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបង្កើតឡើង កាតព្វកិច្ចនឹងកើតមានដូចគ្នា ដែលដូចជាការទូទាត់ប្រាក់ និងការដឹកជញ្ជូនទំនិញ។ បញ្ហាដែលតែងកើតមានជាញឹកញាប់គឺ ការទូទាត់ប្រាក់រួចរាល់ប៉ុន្តែមិនទទួលបានទំនិញ ឬ ការទទួលបានទំនិញរួចរាល់ប៉ុន្តែមិនធ្វើការទូទាត់ប្រាក់។ ជាក់ស្តែងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីមុន អ្នកផ្គត់ផ្គង់ទំនិញ ឬសេវាតែងដាក់ទំនិញជូនទៅកាន់អ្នកទិញជាមុន ទើបទទួលបានការទូទាត់ប្រាក់តាមធនាគារ ឬ តាមអ្នកដឹកជញ្ជូន។ ប៉ុន្តែ បញ្ហាតែងកើតមានឡើងដោយពេលខ្លះអ្នកទិញបានទទួលទំនិញ រួចមិនព្រមធ្វើការទូទាត់ប្រាក់ ឬ ការដឹកជញ្ជូនបានទៅដល់ទីតាំង ប៉ុន្តែអ្នកទិញមិនបានចេញមកទទួលទំនិញនោះជាដើម ដែលធ្វើឱ្យមានការខាតបង់ដល់អ្នកផ្គត់ផ្គង់ទំនិញ ឬសេវា។ ហេតុនេះទើបពេលក្រោយមក មុននឹងដាក់ទំនិញជូនដល់អ្នកទិញ អ្នកផ្គត់ផ្គង់ទំនិញ ឬ សេវាតែងទាមទារក្នុងការទូទាត់ប្រាក់ជាមុន ដោយសារមានការព្រួយបារម្ភថាភាគីនឹងមិនអនុវត្តកាតព្វកិច្ចដូចដែលបានសន្យាគ្នាក្នុងពេលបង្កើតកិច្ចសន្យា។ បន្ថែមពីនេះ នៅពេលខ្លះបន្ទាប់ពីអ្នកទិញបានទូទាត់ប្រាក់ទៅកាន់អ្នកផ្គត់ផ្គង់ទំនិញ ឬ សេវារួចរាល់ ប៉ុន្តែបែរជាមិនទទួលបានទំនិញទៅវិញ ដោយមានការបោកប្រាស់មិនដាក់ទំនិញជូនពីអ្នកផ្គត់ផ្គង់ទំនិញ ឬសេវានោះ។ នេះជាបញ្ហាប្រឈមនៃការមិនទុកចិត្តគ្នាក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនាពេលបច្ចុប្បន្ន។

### ៣.១.២ ភាពកង្វះខាតនៃផ្នែកច្បាប់ និង ផ្នែកបច្ចេកវិទ្យា

ការសម្រេចបាននូវច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តលើវិស័យណាមួយ មិនមែនជាភាពងាយស្រួលទេ ជាពិសេសចំពោះប្រទេសដែលកំពុងអភិវឌ្ឍដូចប្រទេសកម្ពុជា។ ប្រទេសកម្ពុជា បានខិតខំពង្រឹងដោយដាក់ចេញនូវវិធានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគ្របដណ្តប់ និង ការពារ

កុំឱ្យមានការប្រព្រឹត្តទៅដោយមិនសមរម្យ ឬ មានស្នូគស្មាញដល់អ្នកប្រើប្រាស់។ ដោយក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ និង អនុក្រឹត្យ ប្រកាស។ល។ ប៉ុន្តែ ក្នុងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើពាណិជ្ជកម្ម ត្រូវបានបញ្ចូលនូវទិន្នន័យដែលជាអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ ដោយទិន្នន័យទាំងនោះមិនទាន់មានច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តណាមួយការពារតឹងរឹង ឬ បានចែងយ៉ាងជាក់ច្បាស់នោះទេ។ មាត្រា ៣២ នៃច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបញ្ញត្តិអំពីការការពារទិន្នន័យ ដោយបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវប្រើគ្រប់មធ្យោបាយដើម្បីធានាថា ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈ និងសមហេតុផល។[១០៧] ប៉ុន្តែពាក្យថា ធានាការការពារគ្រប់កាលៈទេសៈ និង សមហេតុផលនោះ មិនទាន់មានច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តណាដែលបញ្ជាក់ច្បាស់លាស់ទេ។ ដូច្នេះ មានតែការបកស្រាយរបស់ចៅក្រមប៉ុណ្ណោះ ដែលកំណត់បានថាទិន្នន័យដែលបានការពារស្របតាមកាលៈទេសៈ និង សមហេតុផលមានលក្ខណៈបែបណា។

ទាក់ទងនឹងការការពារទិន្នន័យរបស់អ្នកប្រើប្រាស់ អត្ថិភាពនៃច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតែឯកឯង មិនទាន់គ្រប់គ្រាន់ក្នុងការការពារ និង ដោះស្រាយរាល់បញ្ហាទាក់ទងនឹងការធានាសុវត្ថិភាពទិន្នន័យឱ្យបានខ្ពស់នោះទេ។ ដូច្នេះ ប្រទេសកម្ពុជាត្រូវទាមទារឱ្យមាននូវច្បាប់បន្ថែមទៀតដែលគ្របដណ្ដប់លើការធានាសុវត្ថិភាពទិន្នន័យ។ បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងធ្វើការព្រាងច្បាប់ស្ដីពីការការពារទិន្នន័យ ដែលជាភាសាអង់គ្លេសហៅថា Law on Data Protection និង ច្បាប់ស្ដីពីសន្តិសុខសាយប័រ ដែលជាភាសាអង់គ្លេសហៅថា Law on Cybersecurity។

ចំពោះបញ្ហាប្រឈមដែលកើតមានឡើងដោយកង្វះខាតផ្នែកបច្ចេកវិទ្យាវិញ មិនទាន់មាននូវការធានាសុវត្ថិភាពចំពោះទិន្នន័យដែលបានបញ្ចូល ដោយប្រព័ន្ធបច្ចេកវិទ្យាមិនទាន់មានលំនឹងនៅឡើយ។ ករណីមានការបំពាន (Hack) ចូលក្នុងទិន្នន័យ គឺមិនទាន់មានវិធីណាមួយខ្លាំងក្លា ក្នុងការទាញយកទិន្នន័យមកវិញបាននោះទេ។ ព័ត៌មានដែលបានភ្ជាប់ជាមួយប្រព័ន្ធអ៊ិនធឺណិត ឬ ប្រព័ន្ធអេឡិចត្រូនិកអាចជាគោលដៅមួយសម្រាប់ធ្វើប្រតិបត្តិការក្នុងការលួចយកទិន្នន័យ ឬ អត្តសញ្ញាណ និងក្លែងបន្លំព័ត៌មាន ឬ អត្តសញ្ញាណ ដែលជាការរំលោភបំពានលើឯកជនភាពរបស់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក អាចនឹងប៉ះពាល់ដល់សុវត្ថិភាពទាំងសិទ្ធិបុគ្គល និងផ្នែកហិរញ្ញវត្ថុផ្ទាល់ខ្លួន ជាហេតុ

[១០៧] ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា៣២។

នាំឱ្យមានជាផលវិបាក និងបញ្ហាមួយចំបងដែលត្រូវដោះស្រាយឱ្យបានឆាប់រហ័ស។ ការព្រួយបារម្ភពីការចូលបំពាន និងបាត់បង់ព័ត៌មានដែលបានបញ្ចូល កំពុងបន្តកើតមាននាពេលបច្ចុប្បន្ន។

កង្វះខាតផ្នែកបច្ចេកវិទ្យាក្នុងន័យម្យ៉ាងទៀតនោះគឺ អក្ខរកម្មឌីជីថល និងប្រព័ន្ធសេវា។ ដោយយោងតាមស្ថិតិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI ឆ្នាំ២០២២ ប្រជាជនកម្ពុជាតិចជាង ១ ភាគ ៣ នៃប្រជាជនសរុប មានជំនាញឌីជីថល ដែលជាចំនួនមួយស្ថិតក្នុងកម្រិតទាបនៃអក្ខរកម្មផ្នែកឌីជីថល ហើយក្នុងនោះប្រជាជនត្រឹមតែ ៣០% ប៉ុណ្ណោះដែលមានសមត្ថភាពក្នុងការប្រើប្រាស់អ៊ិនធឺណិតសម្រាប់ទំនាក់ទំនង។ ម្យ៉ាងទៀត ប្រព័ន្ធសេវាអ៊ិនធឺណិត ក៏នៅមានកម្រិតដោយនៅតំបន់មួយចំនួនមិនទាន់មានប្រព័ន្ធសេវាអ៊ិនធឺណិតសម្រាប់ប្រើប្រាស់នៅឡើយ ដែលជាហេតុនាំឱ្យការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនទាន់រីករាលដាលគ្រប់ទិសទី។

### ៣.១.៣ បទល្មើសកើតមានឡើងតាមរយៈការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

បទល្មើសមួយចំនួន អាចកើតមានឡើងតាមរយៈការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសដែលកើតមាននេះ ក្រសួងពាណិជ្ជកម្មបានធ្វើវិសោធនកម្មច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងជំពូកទី ១១ ស្តីពីទោសប្បញ្ញត្តិ។ ដោយក្នុងនោះបានចែងអំពីការផ្តន្ទាទោស និងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះនីតិបុគ្គល ដែលបានប្រព្រឹត្តបទល្មើសចាប់ពីមាត្រា ៥៣ ដល់មាត្រា ៥៥ កថាខណ្ឌទី ២ នៃមាត្រា ៥៦ និងមាត្រា ៥៩ ដល់មាត្រា ៦៤។

បទល្មើសដែលអាចកើតមាន និងការផ្តន្ទាទោសចំពោះបទល្មើសធ្វើឡើងតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានដូចជា៖

តារាង២៖ បទល្មើស និងការផ្តន្ទាទោសក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

| មាត្រា | បទល្មើស | ផ្តន្ទាទោស |
|---|---|---|
| ៥៣ | ការលួចប្រើប្រាស់អត្តសញ្ញាណ | ពន្ធនាគារ ៖ ៦ខែ ទៅ ៣ឆ្នាំ<br>ពិន័យជាប្រាក់ ៖ ១លានរៀល ទៅ ៦លានរៀល |
| ៥៤ | ការមិនរាយការណ៍អំពីព័ត៌មាន | ពន្ធនាគារ ៖ ១ខែ ទៅ ១ឆ្នាំ<br>ពិន័យជាប្រាក់៖ ១សែនរៀល ទៅ ២លានរៀល |
| ៥៥ | ការផ្តល់ព័ត៌មានមិនពិត | ពន្ធនាគារ៖ ១ខែ ទៅ ១ឆ្នាំ |

| | | |
|---|---|---|
| | | ពិន័យជាប្រាក់៖ ១សែនរៀល ទៅ ២លានរៀល |
| ៥៦ | ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត | ពន្ធនាគារ៖ ១ ទៅ ៣ឆ្នាំ<br>ពិន័យជាប្រាក់៖ ២លាន ទៅ ៦លានរៀល |
| ៥៧ | ការមិនអនុវត្តតាមបទប្បញ្ញត្តិ | ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ |
| ៥៨ | ការធ្វើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ | ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ |
| ៥៩ | ការក្លែងប្រព័ន្ធអេឡិចត្រូនិក និងកូដព្យាបាទ | ពន្ធនាគារ៖ ៦ខែ ទៅ ៣ឆ្នាំ<br>ពិន័យជាប្រាក់៖ ១លាន ទៅ ៦លានរៀល |
| ៦០ | ការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ | ពន្ធនាគារ៖ ១ ទៅ ២ឆ្នាំ<br>ពិន័យជាប្រាក់៖ ២លាន ទៅ ៤លានរៀល |
| ៦១ | ការបំពានលើការចេញលិខិតបញ្ជាក់យថាភូត | ពន្ធនាគារ៖ ១ខែ ទៅ ១ឆ្នាំ<br>ពិន័យជាប្រាក់៖ ១សែនរៀល ទៅ ២លានរៀល |
| ៦២ | ការបំពានលើកូដនីយកម្ម | ពន្ធនាគារ៖ ១ ទៅ ៣ឆ្នាំ<br>ពិន័យជាប្រាក់៖ ២លាន ទៅ ៦លានរៀល |
| ៦៣ | ការធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក | ពន្ធនាគារ៖ ១ ទៅ ៥ឆ្នាំ<br>ពិន័យជាប្រាក់៖ ១លាន ទៅ ១០លានរៀល |
| ៦៤ | ការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក | ពន្ធនាគារ៖ ១ ទៅ ៣ឆ្នាំ<br>ពិន័យជាប្រាក់៖ ២លាន ទៅ ៦លានរៀល |

## ៣.២ ដំណោះស្រាយចំពោះបញ្ហាប្រឈម

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កំណត់ទោសប្បញ្ញត្តិមួយចំនួនទាក់ទងនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ទោសប្បញ្ញត្តិទាំងអស់នោះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការផាកពិន័យជាប្រាក់ ការដាក់ពន្ធនាគារ ការបញ្ឈប់ ឬ ការព្យួរសកម្មភាពអាជីវកម្ម ឬប្រតិបត្តិ

ការអាជីវកម្ម និង ការដកហូតអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតក្នុងការប្រកបអាជីវកម្ម។ ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើរតួនាទីសំខាន់ក្នុងការដាក់ពិន័យ ដោយឡែកចំពោះបញ្ហាប្រឈមខ្លះទៀតតម្រូវឱ្យមានស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតចូលរួមការដោះស្រាយ។

ថ្វីត្បិតក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមានចែងអំពីការដោះស្រាយវិវាទដែលកើតឡើងក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅស្ថាប័នផ្សេងក៏ដោយ ក៏អ្នកប្រើប្រាស់គួរទទួលបាននូវការដោះស្រាយបញ្ហាប្រឈមដែលកើតឡើងប្រកបដោយយុត្តិធម៌ តម្លាភាព និងប្រសិទ្ធភាព។ បញ្ហាប្រឈមដែលកើតមាន ត្រូវដោះស្រាយដោយស្ថាប័នដែលមានសមត្ថកិច្ចតាមផ្នែកនៃបញ្ហានោះ ដែលអាចមានដូចជា ស្នងការដ្ឋាននគរបាលរាជធានីខេត្ត ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និង តុលាការ។

### ៣.២.១ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

បញ្ហាប្រឈមដែលកើតមានលើប្រជាពលរដ្ឋ ប៉ះពាល់ដល់សុវត្ថិភាព សន្តិសុខ និង សណ្តាប់ធ្នាប់ គឺប្រជាពលរដ្ឋអាចដោះស្រាយតាមរយៈស្នងការដ្ឋាននគរបាលរាជធានីខេត្តបាន។ ស្នងការដ្ឋាននគរបាលរាជធានីខេត្ត ស្ថិតក្រោមឱវាទអភិបាលនៃគណៈអភិបាលរាជធានីខេត្ត និងការបញ្ជាដឹកនាំជំនាញរបស់អគ្គស្នងការនគរបាលជាតិ ដែលមានសមត្ថកិច្ចការពារ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបស់ប្រជាជន។[១០៨] ក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រសិនបើមានការប្រាសចាក ឬបំពានច្បាប់ ហើយបង្កើតជាបទល្មើស គឺស្នងការដ្ឋាននគរបាលរាជធានីខេត្ត អាចធ្វើការដោះស្រាយដោយមានការនាំខ្លួន ចាប់ខ្លួន ឬឃាត់ខ្លួនជនល្មើសស្របតាមនីតិវិធីច្បាប់។

### ៣.២.២ ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា

នៅក្នុងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ មានការិយាល័យទទួលបន្ទុកផ្នែកប្រឆាំងបទល្មើសបច្ចេកវិទ្យា ដោយការិយាល័យនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដោះស្រាយនូវបញ្ហា ដែលប្រព្រឹត្តដោយជនខិលខូច ឬ តតិយជនណាមួយ ហើយបានប៉ះពាល់ផលប្រយោជន៍របស់អ្នកប្រើប្រាស់។

ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យានេះ មានភារកិច្ចដូចជា៖[១០៩]

[១០៨] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានីខេត្ត, លេខ១៣៣០០ ប្រ.ក, ២៩ វិច្ឆិកា ២០១៦, ប្រការ១។

[១០៩] ដដែល, ប្រការ៤។

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា
- សហការជាមួយសាខាចែកចាយសេវាទូរគមនាគមន៍គ្រប់ប្រភេទ ដើម្បីត្រួតពិនិត្យការចុះបញ្ជី ភ្ជាប់ ប្រើប្រាស់សេវាទូរគមនាគមន៍ និងបច្ចេកវិទ្យាតាមការកំណត់
- សហការជាមួយស្ថាប័នរដ្ឋ និងឯកជន ដែលធ្វើអាជីវកម្មសេវាហិរញ្ញវត្ថុ ដើម្បីស្រាវជ្រាវស៊ើប អង្កេត ប្រមូលភស្តុតាង និងបង្ក្រាបបទល្មើសហិរញ្ញវត្ថុតាមប្រព័ន្ធបច្ចេកវិទ្យា
- តាមដានប្រមូលព័ត៌មានលើបណ្ដាញសង្គម និងអ៊ិនធឺណែត វិភាគវាយតម្លៃសភាពការណ៍បង្ក អសន្តិសុខ និងអស្ថិរភាពសង្គម
- ស្រាវជ្រាវស៊ើបបញ្ជាក់ ប្រមូលភស្តុតាង និងសាវតារបស់គណនីមុខសញ្ញាប្រព្រឹត្តបទល្មើស តាម បណ្ដាញសង្គមបច្ចេកវិទ្យា ដើម្បីកសាងសំណុំរឿងតាមនីតិវិធី
- ធ្វើរបាយការណ៍ស្រាវជ្រាវករណី និងប្រមូល គ្រប់គ្រងវត្ថុតាងជូននាយកដ្ឋានប្រឆាំងបទល្មើស បច្ចេកវិទ្យា ដើម្បីផ្ដល់ការណែនាំជំនាញបច្ចេកទេស និងការធ្វើកោសល្យវិច័យបច្ចេកវិទ្យាតាម នីតិវិធី
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និង លើកទិសដៅការងារជូន ស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឱ្យ។

តាមរយៈភារកិច្ចខាងលើ ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យាត្រូវធានាឱ្យបាននូវសុវត្ថិភាព បច្ចេកវិទ្យា ប្រឆាំង និងដោះស្រាយបទល្មើសបច្ចេកវិទ្យាផ្សេងៗដែលកើតមាននៅក្នុងប្រទេសកម្ពុជា។

### ៣.២.៣ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់

ចំពោះកិច្ចការពារអ្នកប្រើប្រាស់ដែលបានលើកឡើងនូវចំណុច ២.៣ គឺគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់មានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្ដឹង ស៊ើបអង្កេត និង ប្រមូលភស្តុតាងពាក់ព័ន្ធនឹងការបំពានលើបញ្ញត្តិណាមួយក្នុងច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់។[១១០] មន្ត្រីស៊ើបអង្កេត អាចធ្វើការត្រួតពិនិត្យ ស្រាវជ្រាវ សាកសួរ ឆែកឆេរ និងចាត់វិធានការនានាមុននឹងចេញសេចក្ដីសម្រេច ឬ កំណត់ទណ្ឌកម្មរដ្ឋបាល។[១១១] ក្រោយចេញសេចក្ដីសម្រេច ប្រសិនបើបុគ្គលនោះមិនសុខចិត្ត អាចប្ដឹង

[១១០] ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា២៨។
[១១១] ដដែល, មាត្រា៣២។

តវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចចុងក្រោយ។[១១២]

### ៣.២.៤ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

ទន្ទឹមនឹងការដោះស្រាយវិវាទ ឬ បញ្ហាប្រឈមដែលកើតមានឡើងក្នុងវិស័យពាណិជ្ជកម្ម ភាគីនៃការធ្វើពាណិជ្ជកម្មអាចធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបាន តាមរយៈមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម) ដែលជាភាសាអង់គ្លេសហៅថា National Commercial Arbitration Centre (NCAC)។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញមួយ ដែលផ្តល់ឱ្យសហគមន៍ពាណិជ្ជករនូវយន្តការដោះស្រាយវិវាទពាណិជ្ជកម្មមួយក្រៅប្រព័ន្ធតុលាការ។[១១៣] ការដោះស្រាយវិវាទតាមប្រព័ន្ធមជ្ឈត្តការ ប្រព្រឹត្តទៅតាមរយៈច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលបានប្រកាសឱ្យប្រើ និង វិធានច្បាប់របស់មជ្ឈមណ្ឌលមជ្ឈត្តការ។ មជ្ឈត្តករគឺជាបុគ្គលដែលធ្វើការសម្របសម្រួល ដើម្បីរកនូវដំណោះស្រាយឈ្នះឈ្នះឱ្យភាគីទាំងសងខាង បង្រួមពេលវេលា និងថវិកាដែលត្រូវចំណាយ និងទទួលបាននូវមជ្ឈត្តវិនិច្ឆ័យមួយប្រកបដោយប្រសិទ្ធិភាព និងតម្លាភាព។

### ៣.២.៥ តុលាការ

ទោះបីជា ប្រទេសកម្ពុជានាពេលបច្ចុប្បន្នមិនទាន់មានតុលាការពាណិជ្ជកម្ម ដែលជាតុលាការមានសមត្ថកិច្ច និងផ្តោតសំខាន់លើផ្នែកពាណិជ្ជកម្មក៏ដោយ ការដោះស្រាយវិវាទ ឬបញ្ហាប្រឈមរវាងគូភាគីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចដោះស្រាយតាមរយៈសាលាជម្រះក្តីបាន គឺសាលាដំបូងរាជធានីខេត្ត។ សាលាដំបូងរាជធានីខេត្ត គឺជាសាលាជម្រះក្តីដែលមានអំណាចតុលាការ គ្របដណ្តប់គ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។[១១៤] ភាគីដែលបានរងការបំពានដោយសារការមិនគោរពកាតព្វកិច្ច ឬការបោកបញ្ឆោតរបស់ភាគីម្ខាងទៀត អាចដាក់ពាក្យបណ្តឹងមកសាលាដំបូងរាជធានីខេត្ត ហើយការដោះស្រាយនឹងធ្វើឡើងតាមនីតិវិធីដែលបានកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

[១១២] ដដែល, មាត្រា៣៩។
[១១៣] មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, "ហេតុអ្វីជ្រើសរើសមជ្ឈត្តការ?", ២៩ សីហា ២០២៤។
[១១៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, មាត្រា១២៨ ថ្មី។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបង្កើនភាពងាយស្រួលក្នុងការធ្វើជំនួញរបស់ប្រជាពលរដ្ឋទូទាំងប្រទេស។[១១៥] ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកក្នុងការធ្វើពាណិជ្ជកម្ម មានសន្ទុះរីកចម្រើនយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់ ជាហេតុនាំឱ្យការយល់ដឹងអំពីក្របខណ្ឌគតិយុត្តលើវិស័យនេះមានសារៈសំខាន់ ជាពិសេសដើម្បីឱ្យការប្រព្រឹត្តទៅនៃពាណិជ្ជកម្មនេះប្រកបដោយភាពរលូន ហើយយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចដែលច្បាប់បានគាំពារ។

ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានត្រឹមត្រូវ និងស្របតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ គឺជាចំណុចសំខាន់ដែលធ្វើឱ្យការធ្វើពាណិជ្ជកម្មប្រព្រឹត្តិទៅបានរលូន និងជៀសផុតពីហានិភ័យផ្សេងៗ។ នៅពេលដែលកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបង្កើតឡើងមិនស្របតាមលក្ខខណ្ឌច្បាប់កំណត់ នោះកិច្ចសន្យានឹងមិនអាចអនុវត្តបាន ឬមិនមានអានុភាព ដែលនាំឱ្យភាគីនៃកិច្ចសន្យាបាត់បង់ផលប្រយោជន៍ ហើយរាល់សិទ្ធិ និងកាតព្វកិច្ចមិនអាចកើតមានឡើង។ បន្ថែមពីនេះ នៅពេលកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបង្កើតបានត្រឹមត្រូវ និងមានអានុភាព កិច្ចសន្យានោះមានតម្លៃគតិយុត្តស្មើនឹងកិច្ចសន្យាដែលធ្វើឡើងជាលាយលក្ខណ៍ដែរ ដោយមិនមាននរណាអាចអះអាងបដិសេធអំពីតម្លៃគតិយុត្តនៃកិច្ចសន្យានេះបានទេ។[១១៦]

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានគាំពារដល់អ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើពាណិជ្ជកម្មបានយ៉ាងល្អ និងជាក់លាក់ ដោយបានបញ្ញត្តិច្បាស់ពីការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កិច្ចការពារដល់អ្នកប្រើប្រាស់ និងទោសប្បញ្ញត្តិនានា។ ប៉ុន្តែច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសផ្សេងៗទៀតនៅតែជាតម្រូវការក្នុងការបង្កើតបន្ត ដើម្បីគ្រប់គ្រងរាល់បញ្ហាប្រឈមជាក់លាក់ផ្សេងទៀតដែលអាចកើតមានឡើង នៅពេលធ្វើពាណិជ្ជកម្ម ឬប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

[១១៥] International Trade Administration, *Cambodia- Country Commercial Guide* [ការណែនាំផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា], eCommerce, ២០២៤។
[១១៦] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា១៣។

# អនុសាសន៍

# អនុសាសន៍

ក្រសួងក្នុងវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយនិងទូរគមនាគមន៍ និងក្រសួងយុត្តិធម៌ជាដើម គប្បីពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែម ដើម្បីឱ្យការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រព្រឹត្តទៅកាន់តែរលូន និងមានភាព ងាយស្រួល ជាងមុន តាមរយៈការពង្រឹងផ្នែកធនធានមនុស្ស ផ្នែកបច្ចេកវិទ្យា ផ្នែកច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នានាក្នុងការបំពេញបន្ថែមលើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលកំពុងមាន។ ក្រសួង យុត្តិធម៌ និងក្រសួងពាក់ព័ន្ធ គួរដាក់ចេញនូវវិធានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗបន្ថែមដូចជា ច្បាប់ស្តីពីការការពារទិន្នន័យរបស់អ្នកប្រើប្រាស់ជាដើម។ ដូចនេះ ការពន្លឿននូវនីតិវិធីនៃការបង្កើត ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបន្ថែម គឺជាការចាំបាច់ដែលជៀសពុំបាន។

រាជរដ្ឋាភិបាល គប្បីដាក់ចេញនូវគោលនយោបាយ និងយន្តការអនុវត្តបន្ថែម ដោយធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញទន់ទាក់ទិននឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ការបណ្តុះបណ្តាល ធ្វើឱ្យអ្នកប្រើប្រាស់កាន់តែយល់ច្បាស់បន្ថែមពីការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកក្នុងការធ្វើពាណិជ្ជកម្ម ព្រមទាំងសិទ្ធិ និងករណីយកិច្ចរបស់ខ្លួន។ ចំណែក ការពង្រឹងផ្នែកបច្ចេកវិទ្យាវិញ គឺរាជរដ្ឋាភិបាល គួរធ្វើការបណ្តុះបណ្តាល និងស្វែងយល់បន្ថែមអំពីនីតិវិធីក្នុងការដោះស្រាយបញ្ហាដែលកើតឡើង ដូចជាបញ្ហាពាក់ព័ន្ធនឹងការការពារប្រព័ន្ធទិន្នន័យ និងព័ត៌មានសម្ងាត់ដែលអ្នកប្រើប្រាស់បានបញ្ចូល។

# គន្តនិខ្មេល

# គន្ថនិទ្ទេស

## ១. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣។

ច្បាប់ស្តីពីសារពើពន្ធ, លេខ នស/រកម/០៥២៣/០០៤, ១៦ ឧសភា ២០២៣។

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩។

ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់, លេខ នស/រកម/១១១៩/០១៦, ២ វិច្ឆិកា ២០១៩។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១២០៧/០៣០/, ០៨ ធ្នូ ២០០៧។

អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លេខ៤៣ អនក្រ.បក, ២៨ កុម្ភៈ ២០២២។

អនុក្រឹត្យស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ៦៥ អនក្រ.បក, ០៨ មេសា ២០២១។

អនុក្រឹត្យស្តីពី ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណដល់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង, លេខ១៣៤ អនក្រ.បក, ០៧ សីហា ២០២០។

អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦ អនក្រ.បក, ២៩ ធ្នូ ២០១៧។

ប្រកាសរបស់ក្រសួងពាណិជ្ជកម្មស្តីពីការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ២៩០ ព.ណចបព.ប្រក, ៩ តុលា ២០២០។


## ២. ឯកសារជាខេមរភាសា


Fumie, Fukuoka និង Umemoto Yumi. "*បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី.*" ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ. ១៥ មិថុនា ២០២០។

គុណ រក្សា. "តើឧស្សាហកម្ម៤.០គឺជាអ្វី? បដិវត្តឧស្សាហកម្មមានអ្វីខ្លះ?". Medium (១១ មករា ២០២៣) ។

ចិន ស្រីពេជ្រ. "ការវិវត្តនៃបដិវត្តឧស្សាហកម្ម". The Seed គ្រាប់ពូជកម្ពុជា (១៨ តុលា ២០២១) ។

ជួន ណាត. *វចនានុក្រមខ្មែរ*. ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨។

តាន់ មន្នីរិសាល. "បដិវត្តន៍ឧស្សាហកម្មទី ៤". អត្ថបទជំនួយស្មារតី (០៤ មិថុនា ២០១៩) ។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម. "ហេតុអ្វីជ្រើសរើសមជ្ឈត្តការ?." ២៩ សីហា ២០២៤។

រដ្ឋាភិបាលកម្ពុជា. *យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១*. ២០២៣។

ហាប់ ផល្លី. *វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា*. បោះពុម្ពលើកទី៣. ភ្នំពេញ៖ Premium Advertising, ២០២១។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ. *កម្រងសំណួរដែលសួរជាញឹកញាប់ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*. ភ្នំពេញ៖២០២២. https://www.facebook.com/story.php/?story_fbid=៣២២៥១១២៨៣៣៧៩៦២៣&id=១០០០៦៨៦២២៦២០០៣៥ ។

អាន សុវឌ្ឍនា. "ទម្រង់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក." បទបង្ហាញសម្រាប់និស្សិតបរិញ្ញាបត្រនីតិសាស្ត្រសិក្សាជាភាសាអង់គ្លេស, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ២៤ តុលា ២០២៣។

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ. "*ក្របខណ្ឌ និងគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥.*" ២០២១។

### ៣. ឯកសារជាភាសាបរទេស

Davidson, Alan. ២០១៦. *Social Media And Electronic Commerce Law* [ប្រព័ន្ធផ្សព្វផ្សាយសង្គម និងច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក]. Australia: Cambridge University Press Second Edition។

Emudhra Trust Delivered. "What is the difference between a Digital Signature and an Electronic Signature?" [តើអ្វីជាភាពខុសគ្នារវាងហត្ថលេខាឌីជីថល និងហត្ថលេខាអេឡិចត្រូនិក?]. គ្មានកាលបរិច្ឆេទ។

GlobalSign Blog. "Everything You Need to Know about Electronic and Digital singatures" [អ្វីដែលអ្នកត្រូវយល់ដឹងអំពីហត្ថលេខាអេឡិចត្រូនិកនិងហត្ថលេខាឌីជីថល], ២០២៣។

GoCardless. "The Basics of Online Payment Processing" [មូលដ្ឋាននៃនីតិវិធីនៃការទូទាត់ប្រាក់តាមរយៈប្រព័ន្ធអនឡាញ], ២០២៣។

International Trade Administration. "Cambodia- Country Commercial Guide" [ការណែនាំផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា]. ២០២៤។

Ismail, Yasmin. "E-commerce in the World trade Organization" [ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក]. ២០២០។

Profitence (Cambodia) Co., Ltd. "E-Commerce in Cambodia" [ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា]. ២០២៣។

Sargunaraj, Nadarashnaraj. "Electronic & Digital Signatures in ASEAN" [ហត្ថលេខាអេឡិចត្រូនិកនិងហត្ថលេខាឌីជីថលនៅក្នុងអាស៊ាន]. គ្មានកាលបរិច្ឆេទ។

United Nations Commission on International Trade Law. "UNCITRAL Model Law on Electronic Commerce" [ច្បាប់គំរូស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក]. ១៩៩៦។